# មាគ៌ាឆ្ពោះទៅរក សមភាព យេនឌ័រ



បកប្រែ និងរៀបរៀងដោយ

**អង្គការស៊ីលការ**

ខែ ធ្នូ ឆ្នាំ ២០០៥


United Nations Development Fund for Women
UNIFEM

UNDP

JAPAN

United Nations
Development Fund for Women

UNIFEM

UNIFEM is the women's fund at the United Nations. It provides financial and technical assistance to innovative programmes and strategies that promote women's human rights, political participation and economic security. UNIFEM works in partnership with UN organizations, governments and non-government organization (NGOs) and networks to promote gender equality. It links women's issues and concerns to national, regional and global agendas by fostering collaboration and providing technical expertise on gender mainstreaming and women's empowerment strategies.

This publication has been development in cooperation and with support of the GTZ sector project

"Strengthening Women's Rights" on behalf of the German Federal Ministry for Economic Cooperation and Development (BMZ).

Written by Lee Waldorf, with research by Shelley Inglis

Acknowledgements:
A number of individuals have provided suggestions and support that have greatly assisted in the development of this publication, and we would particularly like to thank Barbara Adams, Carol Barton, Mara Bustelo, Nanette Braun, Noeleen Heyzer, Chandni Joshi, Osnat Lubrani, Zina Mounla, Juliane Osterhaus, Leigh Pasqual, Joanne Sandler, Hanna Beate Schoepp-Schilling and Damira Sartbaeva for their contributions.

Pathway to Equality: CEDAW, Beijing and the MDGs
Copyright ©United Nations Development Fund for Women
ISBN: 1-932827-17-X



# មាតិកា


| | |
|---|---|
| សេចក្ដីផ្ដើម | ១ |
| អារម្ភកថា | ៣ |
| របៀបវារៈសហស្សវត្សរ៍នៃសមភាពយេនឌ័រ | ៦ |
| កំណត់សមភាពយេនឌ័រទៅក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ | ១២ |
| ផ្សារភ្ជាប់គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ទៅនឹង CEDAW និងកិច្ចប្រជុំប៉េកាំង | ១៨ |
| គោលដៅទី ១ | ២០ |
| គោលដៅទី ២ | ២៦ |
| គោលដៅទី ៣ | ៣០ |
| គោលដៅទី ៤ និង ៥ | ៣៦ |
| គោលដៅទី ៦ | ៤០ |
| គោលដៅទី ៧ | ៤៤ |
| គោលដៅទី ៨ | ៤៨ |
| ធនធានព័ត៌មានអេឡិចត្រូនិច | ៥២ |
| ឯកសារយោង | ៥៣ |

# សេចក្តីផ្តើម

ប្រទេសកម្ពុជាបានចុះសន្ធិសញ្ញាជាច្រើន នៅពេលដែលសន្ធិសញ្ញាទីក្រុងប៉ារីសត្រូវបានបង្កើតឡើង នៅចុងឆ្នាំ ១៩៩១ ។ ក្នុងចំណោមសន្ធិសញ្ញាទាំងនោះមាន អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងលើស្ត្រីភេទ (CEDAW) ហើយដែលមានកិច្ចប្រជុំបេកាំង នៅឆ្នាំ ១៩៩៥ ដើម្បីដាក់វិធានការអនុវត្ត និងដាក់ចេញនូវកាតព្វកិច្ចសម្រាប់ប្រទេសជាហត្ថលេខីទាំងឡាយដែលក្នុងនោះមានប្រទេសកម្ពុជាមួយផងដែរ ។

សន្ធិសញ្ញា CEDAW ជាសន្ធិសញ្ញាចែងអំពីសិទ្ធិរបស់ស្ត្រី ដែលជាមធ្យោបាយ និងមាគ៌ាចាំបាច់ ក្នុងការអភិវឌ្ឍន៍និងក្នុងការកាត់បន្ថយភាពក្រីក្រ ។

នៅក្នុងឆ្នាំ ២០០០ ប្រទេស ១៨៩ ដែលជាសមាជិកអង្គការសហប្រជាជាតិ បានចុះសន្ធិសញ្ញាទទួលយក គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (MDGs) ដើម្បីលើកទ្រទ្រង់សំរាប់ឆ្ពោះទៅមុខធ្វើឱ្យមានសមភាពយេនឌ័រ ។ គោលដៅទាំងនេះជាសក្តានុពលដ៏ប្រសើរ ហើយជាមធ្យោបាយ ដែលត្រូវយកចិត្តទុកដាក់លើកកម្ពស់សមភាពយេនឌ័រ ដោយគិតថាជោគជ័យនៃគំរោងកាត់បន្ថយភាពក្រីក្រ គឺអាស្រ័យដោយសក្តានុពលនៃការចូលរួមរបស់ស្ត្រី ។

សៀវភៅនេះបានរៀបចំឡើងដោយ UNIFEM ក្នុងគោលបំណងបញ្ជ្រាបសន្ធិសញ្ញា CEDAW និងកិច្ច ប្រជុំបេកាំងទៅក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (MDGs) ដែលជាមាគ៌ាឆ្ពោះទៅរកសមភាពយេនឌ័រហើយ ជាឧបករណ៍ចាំបាច់ ក្នុងការរៀបចំយុទ្ធសាស្ត្រ និងវិធានការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍ប្រកបដោយចីរភាព ។

អង្គការសីលការ យល់ឃើញថា ខ្លឹមសារនៃសៀវភៅនេះ និងជួយជាចំណេះដឹង និងជាឧបករណ៍ ក្នុងការរៀបចំអនុវត្តន៍ និងការតាមដានវាយតម្លៃរាល់កម្មវិធីរបស់ស្ថាប័នជាតិ និងសង្គមស៊ីវិលទាំងអស់ ក្នុងការសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (CMDG) ។

ការបកប្រែ និងបោះពុម្ពផ្សាយសៀវភៅនេះឋិតនៅក្រោមកម្មវិធីយេនឌ័រ និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ។ យើងខ្ញុំសូមថ្លែងអំណរគុណដល់ម្ចាស់ជំនួយទាំងអស់ រួមមាន UNIFEM, UNDP និង Japan Wid Fund ដែលផ្តល់លទ្ធភាព ក្នុងការបោះពុម្ពសៀវភៅឯកសារនេះ ។

**ធីដា ឃុះ**

នាយិកាអង្គការសីលការ



NOELEEN HEYZER
នាយិកាប្រតិបត្តិ UNIFEM

សេចក្ដីប្រកាសសហស្សវត្សរ៍ និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (MDGs) បានបើកច្រកថ្មីសំរាប់ឈានឆ្ពោះទៅមុខនៃសមភាពយេនឌ័រ ។ គោលដៅទាំងនេះ ដែលធ្លាប់ជាសក្ដានុពលដ៏ប្រសើរនោះ អាចជាមធ្យោបាយ ដែលតាមរយៈនេះ ការទំនាក់ទំនង រវាងវិសមភាពយេនឌ័រ ការមិនយកចិត្តទុកដាក់ការបង្ហោកបង្ហាបសក្ដានុពលមនុស្សជាស្ត្រី និងការចេះតែបន្តវិលវល់ភាពក្រីក្រ ត្រូវបានគេផ្ដោតយកចិត្តទុកដាក់ ហើយជាចុងក្រោយទទួលបានជោគជ័យ ។ សេចក្ដីប្រកាសគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍នោះ បានទទួលស្គាល់ថាការកាត់បន្ថយកំរិតនៃភាពក្រីក្រដែលប្រកបដោយអត្ថន័យខ្លឹមសារ និងនិរន្តរភាពនោះវាអាស្រ័យលើឆន្ទៈរបស់យើងក្នុងការប្រឈមមុខចំពោះតថភាពជាក់ស្ដែង ដែលពាក់កណ្ដាលនៃប្រជាពលរដ្ឋពិភពលោក មានយុវតី និងស្ត្រី ហើយពួកគេទាំងនោះ មិនទទួលផលប្រយោជន៍ និងស្ថិតនៅក្នុងភាពរងគ្រោះជាប្រព័ន្ធ ។ កិច្ចការនេះអាស្រ័យលើការតាំងចិត្ត មិនងាករេរបស់យើង ចំពោះជំហានចាំបាច់ដើម្បីលុបបំបាត់នូវវិសមភាពនេះ ។

ដោយសារតែគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ បានក្លាយជាចំណុចស្នូលនៃកម្មវិធីរួមដែលលើកឡើងដោយដៃគូអភិវឌ្ឍន៍ទាំងអស់ រួមទាំងសហគមន៍ផ្ដល់ជំនួយអភិវឌ្ឍន៍ផងដែរ ដោយពួកគេទាំងអស់គ្នាមើលឃើញថាវា ជាក្បាលម៉ាស៊ីនសំរាប់ការផ្លាស់ប្ដូរដែលប្រកបដោយប្រសិទ្ធភាពយ៉ាងពិតប្រាកដមួយ ។ ប៉ុន្តែអ្វីកាន់តែមានសារៈសំខាន់ ជាងភាពជាក់ស្ដែងនៃភាពល្អមធ្យមក្នុងកម្មវិធីអភិវឌ្ឍន៍គឺ



HEIDEMARIE WIECZORK-ZEUL
រដ្ឋមន្ត្រីក្រសួងសហប្រតិបត្តិការ សេដ្ឋកិច្ចនិងអភិវឌ្ឍន៍

ជាការសម្រេចជាឯកឆន្ទ ក្នុងកិច្ចខិតខំប្រឹងប្រែង ដើម្បីសំរេចឱ្យបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍នោះ គេត្រូវតែដាក់បញ្ចូលទស្សនវិស័យដែលបានចែងស្រាប់ នៅក្នុងសេចក្ដីប្រកាសសហស្សវត្សរ៍ ។ នៅពេលដែលគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ត្រូវបានកំណត់ច្បាស់ ដោយមានពេលវេលាច្បាស់លាស់ អាចវាស់វែងបាន មានចំណុចដៅនិងសូចនករសំរាប់ការកាត់បន្ថយភាពក្រីក្រនោះ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ទាំងនោះអាចផ្ដល់អោយយើងនូវការបើកផ្លូវដ៏ទូលំទូលាយមួយ សម្រាប់គំរោងការងារ ដែលត្រូវចាប់ផ្ដើម



# អារម្ភកថា

ធ្វើ ។ សេចក្តីប្រកាសសហស្សវត្សរ៍នោះ ស្ថិតជាមិនទៅតែជាមគ្គុទ្ទេសក៍របស់យើង សំរាប់ធ្វើអោយគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ក្លាយជាការពិត និងអ្វីដែលសេចក្តីប្រកាសនោះបញ្ជាក់ប្រាប់យើង គឺជាការខិតខំប្រឹងប្រែង ដើម្បីអនុវត្តនូវការតាំងចិត្តដែលបានប្រកាសនៅក្នុងសន្និសីទពិភពលោក និងធ្វើអោយច្បាប់អន្តរជាតិមានលក្ខណៈទៅតាមគំរូនៃសិទ្ធិមនុស្ស ទៅតាមអ្វីដែលមិនធ្លាប់មានពីមុន ។ សេចក្តីប្រកាសសហស្សវត្សរ៍នាំយើងឆ្ពោះទៅរកតម្រូវការបន្ទាន់សំរាប់ការដោះស្រាយរួមដើម្បី កាត់បន្ថយភាពក្រីក្រ ។ ការប្រយុទ្ធប្រឆាំងនឹងមេរោគដូចជា ការជំរុញលើកស្ទួយសមភាពយេនឌ័រ ការប្រយុទ្ធប្រឆាំង ជំងឺអេដស៍ និងការពង្រឹងភាពជាដៃគូសាកលសំរាប់ការអភិវឌ្ឍន៍ គឺជាការយកចិត្តទុកដាក់សំខាន់ៗ ដែលត្រូវមាន ជាជាគោលការណ៍នៅក្នុងសិទ្ធិផ្ទាល់ខ្លួនរបស់ពួកគេជាស្ត្រី ។ ប៉ុន្តែការនេះមិនគួរត្រូវវិនាស ដល់ការយកចិត្តទុកដាក់ពីការងារដែលត្រូវធ្វើ ដើម្បីសំរេចគោលបំណងរបស់គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ឡើយ ។ ការវិភាគលំអិត នៃជំងឺអេដស៍គឺកាន់តែបង្ហាញយ៉ាងច្បាស់ពីទំនាក់ទំនងរវាងផលសម្រេចបាននៃគោលដៅនីមួយៗទៀត ។ ប្រសិនបើកិច្ចសហប្រតិបត្តិការលើការអភិវឌ្ឍន៍មិនស្របតាមនឹងការសម្រេចចិត្តសម្រាប់គាំទ្រដល់សមិទ្ធផលនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ទាំងអស់នោះទេ ការខិតខំប្រឹងប្រែងថ្នាក់ជាតិអាចមិនទទួលបានផលប្រយោជន៍អ្វីទាំងអស់ ។ ម្យ៉ាងទៀត សៀវភៅតូចនេះរៀបរាប់ពិស្តារ ជាពិសេស វិសមភាពយេនឌ័រអាចស៊ីគ្នាជាក្រុមមួយជាមួយនិងកិច្ចដំណើរការព្យាយាមអនុវត្តគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ដែលបានដាក់ចេញ ។

សៀវភៅតូចនេះក៏បានគូសបញ្ជាក់ថា អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងចំពោះស្ត្រី និងសន្និសីទលើកទី៤ នៅទីក្រុងប៉េកាំងស្តីអំពីស្ត្រីត្រូវតែជាគំរូរបស់យើងសំរាប់សម្រេចសក្តានុពល ដែលបានកំណត់ដោយគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ។ ភាពយល់ដឹងគ្រប់ជ្រុងជ្រោយ និងបទពិសោធន៍អំពីលក្ខណៈដើម យេនឌ័រមានមូលដ្ឋានពីការរើសអើង និងជំហានចាំបាច់ដើម្បីសម្រេចសមភាពយេនឌ័រ ដែលបានបង្កើតឡើងតាមរយៈ CEDAW និងសន្និសីទក្រុងប៉េកាំង រង់ចាំនិងយកមកប្រើប្រាស់ ។ ដោយប្រើឧបករណ៍ CEDAW និងកិច្ចប្រជុំប៉េកាំងជាមូលដ្ឋាន ដើម្បីឆ្លុះបញ្ចាំងឱ្យឃើញគម្លាត និងអនុវត្តគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ការជឿជាក់ជាគោលការណ៍និងការពង្រីកប្រសិទ្ធភាព អាចមានរួមគ្នាប្រកបដោយអត្ថិភាពខ្លាំងក្លា ។



# អារម្ភកថា

ទស្សនវិស័យដែលបានបង្ហាញអោយឃើញច្បាស់ នៅក្នុងសេចក្តីប្រកាសសហស្សវត្សរ៍ គឺជាទស្សនវិស័យមួយ ដែលមូលនិធិសហប្រជាជាតិសំរាប់ស្ត្រី (UNIFEM) និង ក្រសួងសហព័ន្ធដើម្បីសហប្រតិបត្តិការសេដ្ឋកិច្ច និង អភិវឌ្ឍន៍ អាល្លឺម៉ង់ (BMZ) ចូលរួមចំណែកយ៉ាងពេញលេញ ។ BMZ ផ្តល់សារៈសំខាន់ខ្ពស់ចំពោះការយល់ដឹងអំពីសិទ្ធិមនុស្សជាស្ត្រី ជាជាគោលដៅអភិវឌ្ឍន៍ នៅក្នុងសិទ្ធិរបស់ខ្លួន និងចាត់ទុកថាជាមធ្យោបាយសំខាន់ ដើម្បីសម្រេចបាននូវការកាត់បន្ថយភាពក្រីក្រ និងការអនុវត្តន៍ប្រកបដោយនិរន្តរភាព ។ UNIFEM បានដាក់បញ្ចូលការយល់ដឹងអំពីសិទ្ធិមនុស្សជាស្ត្រីនៅក្នុងសមភាពយេនឌ័រ ដែលជាក្របខណ្ឌការងារដ៏មានឥទ្ធិពលទៅលើគ្រប់ផ្នែក និងជាគោលដៅចុងក្រោយនៃផ្នែកទាំងអស់របស់កិច្ចការរបស់ខ្លួន ចាប់តាំងពីផ្នែកអភិវឌ្ឍន៍សេដ្ឋកិច្ច ការកសាងសន្តិភាព រហូតដល់ការប្រឆាំងនឹងការរីករាលដាលនៃជំងឺអេដស៍ និងអំពើហិង្សាលើស្ត្រី ។ UNIFEM និង BMZ សង្ឃឹមថា ធនធាននេះនឹងនៅជាការចូលរួមវិភាគទានយ៉ាងសំខាន់ចំពោះកិច្ចការដែលយើងកំពុងខំប្រឹងធ្វើ ដើម្បីធ្វើអោយការសន្យានៃសេចក្តីប្រកាសសហស្សវត្សរ៍ក្លាយជាការពិត ដោយរួមគ្នាធ្វើជាអ្នកតស៊ូមតិខាងសមភាពយេនឌ័រ ជុំវិញពិភពលោក ។

| | |
|---|---|
| **NOELEEN HEYZER** | **HEIDEMARIE WIECZORK-ZEUL** |
| នាយិកាប្រតិបត្តិ UNIFEM | រដ្ឋមន្ត្រីក្រសួងសហប្រតិបត្តិការ សេដ្ឋកិច្ចនិងអភិវឌ្ឍន៍ |


រូបភាពថតដោយ :

# កម្មវិធី សមភាពយេនឌ័រ ប្រចាំសហស្សវត្សរ៍

គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (MDGs) បានកើតចេញមកពីសេចក្តីប្រកាសសហស្សវត្សរ៍ ដែលមិនធ្លាប់មានពីមុនមក ដែលមានការឯកភាពគ្នាជាសាកលដោយប្រទេសជាសមាជិកអង្គការសហប្រជាជាតិចំនួន ១៨៩ នៅឆ្នាំ ២០០០។ នៅក្នុងសេចក្តីប្រកាសសហស្សវត្សរ៍ សមាជិកអង្គការសហប្រជាជាតិទាំងនោះ រួមគ្នា ធ្វើការជំរុញទស្សនវិស័យជាសាកលនេះ ដើម្បីកែលំអស្ថានភាពមនុស្សជាតិអោយកាន់តែល្អប្រសើរឡើង នៅលើពិភពលោក លើវិស័យអភិវឌ្ឍន៍សន្តិភាពនិងសន្តិសុខ ការការពារបរិស្ថាន ព្រមទាំងសិទ្ធិមនុស្ស និង ប្រជាធិបតេយ្យ ។

ភាពចាំបាច់បំផុតនៃការលើកស្ទួយសិទ្ធិមនុស្ស សំរាប់មនុស្សទាំងអស់ ដើម្បីសំរេចនូវទស្សនវិស័យនេះ ត្រូវបានគូសបញ្ជាក់យ៉ាងច្បាស់នៅក្នុងសេចក្តីប្រកាសនេះ ។ ជាពិសេសការលើកស្ទួយសិទ្ធិស្ត្រីអោយមានភាព ស្មើគ្នានឹងបុរស ត្រូវបានគេទទួលស្គាល់ថាជាការចាំបាច់ឥតប្រកែកបាន សំរាប់ការរីកចំរើន ។ សេចក្តីប្រកាសនេះ ប្តេជ្ញាចិត្តយ៉ាងមុតមាំថា " ប្រឆាំងនឹងអំពើហិង្សាលើស្ត្រីគ្រប់រូបភាព និងអនុវត្តអនុសញ្ញា ស្តីអំពីការលុបបំបាត់ រាល់ទំរង់នៃការរើសអើងលើស្ត្រីភេទ (CEDAW)" ហើយសេចក្តីប្រកាសនេះបន្តទទួលស្គាល់នូវសារៈសំខាន់នៃការលើកស្ទួយសមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី ជាជាមាគ៌ាដ៏មានប្រសិទ្ធភាព ចំពោះការប្រយុទ្ធ ប្រឆាំងនឹងភាពក្រីក្រ ការអត់ឃ្លាន និងជំងឺព្រមទាំងជំរុញយ៉ាងពិតប្រាកដការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ។

ទន្ទឹមគ្នានេះដែរ សេចក្តីប្រកាសសហស្សវត្សរ៍នេះបញ្ជាក់ឡើងវិញនូវគុណតំលៃសំខាន់នៃសមភាពយេនឌ័រ ដែលកើតពីទស្សនវិស័យរបស់សន្និសីទពិភពលោកលើកទី៤ នៃអង្គការសហប្រជាជាតិស្តីពីស្ត្រីនៅទីក្រុងប៉េកាំង ឆ្នាំ ១៩៩៥ និងសន្និសីទពិភពលោកសំខាន់ៗដទៃទៀត ដូចជាសន្និសីទទីក្រុងរីយ៉ូស្តីពីបរិស្ថាន និងការអភិវឌ្ឍន៍ ឆ្នាំ ១៩៩២ សន្និសីទទីក្រុងវីយែនស្តីពីសិទ្ធិមនុស្ស ឆ្នាំ១៩៩៣ សន្និសីទទីក្រុងគែរ៉ូស្តីពីប្រជាពលរដ្ឋ និងការអភិវឌ្ឍន៍ ឆ្នាំ១៩៩៤ សន្និសីទកំពូលពិភពលោក ទីក្រុងកូប៉ិនហាកហ្សេនដើម្បីអភិវឌ្ឍន៍សង្គម ឆ្នាំ១៩៩៥ និងសន្និសីទ ទីក្រុងអ៊ីស្តង់ប៊ុលស្តីពីកតិកាសិទ្ធិមនុស្ស ឆ្នាំ១៩៩៦ ។ សន្និសីទពិភពលោកទាំងអស់នេះ ដែលរៀបចំឡើងដោយអង្គការសហប្រជាជាតិនៅទសវត្សរ៍៩០ បានផ្តល់សន្ទុះសំរាប់សហគមន៍អន្តរជាតិ មកជួបជុំគ្នានៅឯសន្និសីទកំពូលសហស្សវត្សរ៍ ឆ្នាំ២០០០ ដើម្បីយល់ព្រមលើជំហានចាំបាច់ក្នុងការកាត់បន្ថយភាពក្រីក្រ និងស្វែងរកការអភិវឌ្ឍន៍

ប្រកបដោយនិរន្តរភាព ហើយសេចក្តីប្រកាសសហស្សវត្សរ៍បានបង្កើតនូវការប្តេជ្ញាចិត្តថ្មី ដោយប្រទេសសមាជិកទាំងអស់នៅក្នុងសន្និសីទទាំងនេះ ។

ការតាំងចិត្តសំខាន់ៗទាំង ៨ ចំណុច ដែលបានប្តេជ្ញានៅក្នុងសេចក្តីប្រកាសសហស្សវត្សរ៍បានផ្តើមបង្កើតជា **គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍** ដូចខាងក្រោម :

១. ការលុបបំបាត់ភាពក្រីក្រ និងភាពអត់ឃ្លាន

២. សម្រេចនូវការអប់រំបឋមសិក្សាជាសាកល

៣. លើកស្ទួយសមភាពយេនឌ័រ និងផ្តល់អំណាចដល់ស្ត្រី

៤. កាត់បន្ថយមរណៈរបស់កុមារ

៥. ពង្រឹងសុខភាពរបស់មាតា

៦. ប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ ជំងឺគ្រុនចាញ់ និងជំងឺដទៃទៀត

៧. ធានានិរន្តរភាពបរិស្ថាន

៨. ពង្រីកភាពដៃគូជាសាកលដើម្បីការអភិវឌ្ឍន៍

**គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍** (MDGs) មានចំណុចដៅសាកល១៦និងសូចនករសាកល ៤៨ ជាគោលសំរាប់អនុវត្តតាម ។ គោលដៅសហស្សវត្សរ៍ ចំណុចដៅ និងសូចនករនេះបញ្ជាក់នូវការធ្វើកិច្ចការរួមគ្នា ដើម្បីជំរុញសកម្មភាពអោយបានលឿន និងមានប្រសិទ្ធភាពឆ្ពោះទៅរកការសំរេចជោគជ័យ លើការអភិវឌ្ឍន៍ និងការលុបបំបាត់ភាពក្រីក្រតាមទិសដៅនៃសេចក្តីប្រកាស ។ ចំណុចដៅ និងសូចនករ បង្កើតឡើងដើម្បីផ្តល់ ជាខ្នាត ឬរង្វាស់ច្បាស់លាស់វាស់ពីដំណើរការងារដែលប្រទេសទាំងឡាយមានការរីកចំរើន ឆ្ពោះទៅរកការ សំរេចគោលដៅនោះ ហើយដំណើរវិវត្តលាស់នោះ កំពុងត្រូវបានវាស់ប្រមាណជាទៀងទាត់ នៅតាមប្រទេសនីមួយៗ តាមរយៈរបាយការណ៍គោលដៅសហស្សវត្សរ៍ថ្នាក់ជាតិ ។

ការសំរេចបាននូវ **គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍** (MDGs) ត្រូវដាក់ជាអាទិភាពខ្ពស់សំរាប់ដៃគូអភិវឌ្ឍន៍ទាំងអស់ ទាំងរដ្ឋាភិបាលជាតិ ប្រព័ន្ធសហប្រជាជាតិ ក៏ដូចជាស្ថាប័នហិរញ្ញវត្ថុ អន្តរជាតិ ។ ការពិតដែលជាតំរូវការ ដើម្បីដោះស្រាយវិសមភាពយេនឌ័រ ត្រូវបានបញ្ជាក់នៅក្នុងសេចក្តីប្រកាសសហស្សវត្សរ៍ ហើយមានទាំងគោលដៅសមភាពយេនឌ័រ ដែលមានចែងយ៉ាងជាក់លាក់នៅក្នុង

គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ព្រមទាំងមានការទទួលស្គាល់ច្បាស់ថា សមភាពយេនឌ័រជាគោលដៅសំខាន់សំរាប់ធ្វើអោយសំរេចនូវគោលដៅទាំងអស់ ផ្ទុយមកវិញ បានសេចក្តីថា MDGs ផ្តល់នូវឱកាសដ៏មានតម្លៃសំរាប់ជំរុញអោយកម្មវិធី សមភាពយេនឌ័រ ឈានទៅសំរេចគោលដៅ ។

ទោះបីជាយ៉ាងណាក៏ដោយ អ្នកធ្វើការតស៊ូមតិផ្នែកសិទ្ធិមនុស្សអំពីបញ្ហាស្ត្រីជាច្រើន បានកត់សំគាល់ថា សមភាពយេនឌ័រ ដែលជាការព្រួយបារម្ភទាំងអស់គ្នា ដើម្បីសំរេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សទាំងអស់ នោះមិនបានឆ្លុះបញ្ចាំងអោយបានល្អ គ្រប់ជ្រុងជ្រោយនៅក្នុងចំណុចដៅ និងសូចនករជាសាកល[*] ទេ ។ គេមានការព្រួយបារម្ភថា កាតព្វកិច្ច និងការប្តេជ្ញាចិត្តទូលំទូលាយដែលបានដាក់បញ្ចូលទៅក្នុង សន្ធិសញ្ញា CEDAW ក្នុងកិច្ចប្រជុំប៉េកាំងសំរាប់ប្រតិបត្តិការ និងក្នុងឯកសារព្រមព្រៀងថ្នាក់តំបន់ និងថ្នាក់ពិភពលោក ផ្សេងៗទៀត មិនបានបង្ហាញអោយបានល្អ ។ ប៉ុន្តែអ្នកធ្វើការតស៊ូមតិជាច្រើនបានជំនះឧបសគ្គនេះ ដោយអំពាវនាវ អោយមាន ការដាក់បញ្ចូលចំណុចដៅឆ្លើយតបនឹងយេនឌ័រ និងសូចនករនៅកំរិតជាតិបានកាន់តែច្រើន និងទូលំ ទូលាយថែមទៀត ។ សំខាន់ជាងនេះទៀត ចំពោះបញ្ហាវាស់វែង និងការសរសេររបាយការណ៍ ជាការពិតយុទ្ធសាស្ត្រត្រឹមត្រូវដែលនឹងត្រូវប្រកាន់យកដើម្បីសំរេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ត្រូវតែសង្កត់ធ្ងន់លើគំនិត ផ្តួចផ្តើមសមភាពយេនឌ័រ ប្រសិនបើពួកគេចង់បានទទួលជោគជ័យ ។ ដូចដែលរបាយការណ៍ការអភិវឌ្ឍន៍ សិទ្ធិមនុស្សបានបញ្ជាក់ថា "សមភាពយេនឌ័រជាស្នូលនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ដែលត្រូវសំរេចអោយបាន តាំងពីការលើកកំពស់សុខភាព ការប្រយុទ្ធប្រឆាំងនឹងជំងឺនានា ការកាត់បន្ថយភាពក្រីក្រ ចំណាកស្រុកនិងការបំបាត់ការអត់ឃ្លាន ការបង្កើនការអប់រំនិងការបន្ថយមរណៈភាពរបស់កុមារ ការបង្កើនឱកាសទទួលបានទឹកស្អាតប្រើប្រាស់ និងការធានា អោយបាននូវនិរន្តរភាពបរិស្ថាន"[២] ។

មានចន្លោះមួយ សំរាប់ការប្រយុទ្ធប្រឆាំងនឹងវិសមភាពយេនឌ័រ នៅក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ប៉ុន្តែក្នុងនោះការព្រួយបារម្ភអំពីសមភាពយេនឌ័រក្នុងក្របខណ្ឌការងារទូលំទូលាយជាសកល តែងលេចឡើងនៅក្នុង ទ្រង់ទ្រាយសាមញ្ញមួយ ។ តើ MDGs និងបញ្ចូលសហគមន៍អន្តរជាតិ ទៅពិនិត្យមើលជាថ្មី ការដើរថយក្រោយ របស់ខ្លួនពីបញ្ហាស្មុគស្មាញដែលត្រូវតែប្រឈមមុខនៅពេលខាងមុខឬទេ? អ្នកធ្វើការតស៊ូមតិខាងសមភាពយេនឌ័រ បានប្រឹងប្រែងធ្វើការមិនចេះនឿយហត់ ដើម្បីធានាបំពេញកាតព្វកិច្ច និងការប្តេជ្ញាចិត្តក្នុងសន្ធិសញ្ញា CEDAW និងកិច្ចប្រជុំទីក្រុងប៉េកាំងហើយ ឥឡូវនេះមានលទ្ធផលបំភ្លឺនៅក្នុងចំណងច្បាប់ប្រកបដោយយេនឌ័រ ដូចជាមាន វាក្យខណ្ឌដែលក្នុងធម្មនុញ្ញ

មានការសំរេចចិត្តប្រកបដោយការពិចារណា មានគោលនយោបាយ មានរចនាសម្ព័ន្ធ រដ្ឋាភិបាលនិងការបែងចែកធនធាន ដែលនិយាយទាក់ទងដល់សមភាពយេនឌ័រ ។ តើ MDGs នឹងបង្វែរការយកចិត្តទុកដាក់ និងការប្តេជ្ញាចិត្តចេញពីដំណើរការសមភាពយេនឌ័រដែលយើងបានខិតខំធ្វើការ អស់រយៈពេលយូរមកហើយ ដើម្បីប្រសិទ្ធភាពឬយ៉ាងណា?

ឱកាសដែលបានផ្តល់ដោយ MDGs អាចត្រូវចាប់យក ប្រសិនបើយើងនៅតែគោរពតាមស្មារតីនៃ សេចក្តីប្រកាសនោះ ដោយមិនបន្ថយកំរិតគុណភាពនៃការវិភាគ និងយុទ្ធសាស្ត្រសមភាពយេនឌ័រដែលមានស្រាប់ និងដោយមិនធ្វើអោយការទទួលស្គាល់នៃដំណើរការសមភាពយេនឌ័រដែលបានបង្កើតឡើងហើយនោះ ចុះខ្សោយ ។ ការខិតខំប្រឹងប្រែងដើម្បីសំរេចនូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ មិនត្រឹមតែណែនាំ ដោយគោលបំណងចំណុចដៅ និងសូចនាករជាសាកលប៉ុណ្ណោះទេ តែអ្វីដែលសំខាន់ជាងនេះទៅទៀតនោះ គឺការទទួលស្គាល់នូវសារៈសំខាន់ចំបងនៃសេចក្តីប្រកាសសហស្សវត្សរ៍ ចំពោះរាល់ការឈានទៅមុខ នៃការអភិវឌ្ឍន៍ ។

ដូច្នេះវិធីសាស្ត្រនៃការបោះពុម្ពផ្សាយដែលស្នើឡើងនៅក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ មិនចាត់ទុកថាជាកម្មវិធីថ្មីស្របច្បាប់នោះទេ ប៉ុន្តែជាយានថ្មីមួយសំរាប់ការអនុវត្តន៍សន្ធិសញ្ញា CEDAW និងកិច្ចប្រជុំប៉េកាំង ។ មានចំណុចជាច្រើនដែលផ្តល់ផលប្រយោជន៍ អាស្រ័យដោយការចាប់យកសន្ធិសញ្ញា CEDAW កិច្ចប្រជុំប៉េកាំង និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ជាដំណើរការគាំទ្រគ្នាទៅវិញទៅមក ។ ការធ្វើការវិភាគឱ្យបានស៊ីជំរៅ និង ទូលំទូលាយនៃដំណើរការវិសមភាពយេនឌ័រ នៅរាល់ផ្នែក នៃឆាកជីវិតរបស់ស្ត្រី ត្រូវបានបង្កើតឡើងរួចរាល់ហើយ តាមរយៈសន្ធិសញ្ញា CEDAW និងកិច្ចប្រជុំប៉េកាំង និងការងារដែលត្រូវធ្វើស្តីពីគោលដៅអភិវឌ្ឍន៍ សហស្សវត្សរ៍ ។ យុទ្ធសាស្ត្រដែលមានប្រសិទ្ធភាពជាច្រើនសំរាប់ការធ្វើអោយសំរេចនូវសមភាពយេនឌ័រ ត្រូវបានបង្កើតឡើងជាច្រើនទសវត្សរ៍កន្លងមកហើយ តាមរយៈការប្រឹងប្រែង ដើម្បីអនុវត្តនូវសន្ធិសញ្ញា CEDAW និងកិច្ចប្រជុំប៉េកាំង ហើយវិធីសាស្ត្រដែលបានបង្ហាញអាចត្រូវបានបន្ថែមនិងប្រើប្រាស់នៅក្នុងយុទ្ធសាស្ត្រដើម្បីសំរេចនូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ហើយការណ៍នេះមិនគ្រាន់តែជាអ្វីដែលសន្ធិសញ្ញា CEDAW និងកិច្ចប្រជុំប៉េកាំងអាចធ្វើបាន សម្រាប់គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍នោះទេ ។ ប្រសិនបើការប្តេជ្ញាចិត្ត និងធនធាន

ដែលបច្ចុប្បន្ននេះកំពុងត្រូវបានគេរៀបរៀង អាចយកមកប្រើប្រាស់គាំទ្រសកម្មភាព ដើម្បីសំរេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ហើយដែលយើងបានដឹងច្បាស់ពីគុណតម្លៃរបស់សន្ធិសញ្ញា CEDAW និងកិច្ចប្រជុំប៉េកាំងនោះ ការរីកចំរើនក្នុងការអនុវត្តន៍គោលការណ៍ទាំងនោះ និងកើតមានក្នុងកម្រិតក្រោយៗ។

សេចក្តីប្រកាសសហស្សវត្សរ៍អាចជឿតាមគំនិតនេះបាន ប្រសិនបើយើងជ្រើសរើសវា។

## របាយការណ៍គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ថ្នាក់ជាតិ

របាយការណ៍គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ថ្នាក់ជាតិដាក់ផែនការកំណត់អាទិភាព និង ដំណោះស្រាយ ដែលប្រទេសមួយនឹងទទួលយក ដើម្បីសំរេចរាល់គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ។ ចំនួនភាគរយដ៏ច្រើន នៃប្រទេសទាំងឡាយដែលបានអនុវត្ត ដើម្បីសំរេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ឥឡូវនេះកំពុងតែរៀបចំ ឬកំពុងចាប់ផ្តើមរៀបចំរបាយការណ៍ទាំងនោះ ។ ដំណើរការនេះមិនត្រឹមតែផ្តល់ឱកាសសំរាប់ក្របខណ្ឌ ការងារនៃ គោលដៅអភិវឌ្ឍន៍សហសវត្សរ៍ជាសាកលរបស់ប្រទេសនីមួយៗ ដើម្បីអោយមានដំណើរការប្រសើរទៅតាម ស្ថានភាពខ្លួនប៉ុណ្ណោះទេ ប៉ុន្តែមួយផ្នែកទៀត ក៏ចូលរួមចំណែកក្នុងការធ្វើអោយមានសមភាពយេនឌ័រ ក្នុងគោលដៅ នីមួយៗ ឲ្យយកចិត្តដាក់ផងដែរ ។

ដោយខាងមុខនឹងមានបរិយាយពិស្តារនៅក្នុងភាគទី២ បញ្ហាសមភាពយេនឌ័រដែលលើកឡើងក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍នីមួយៗ តែងជាប់ទាក់ទងទាំងស្រុងទៅនឹងសន្ធិសញ្ញា CEDAW និងកិច្ចប្រជុំប៉េកាំង ដូចជាអ្វីដែលជាអត្ថន័យសមភាពយេនឌ័រ និងអ្វីដែលទាមទារឱ្យសំរេចគោលដៅនោះ ហើយដោយមិនមានការផ្លាស់ប្តូរពីក្របខណ្ឌការងារមួយ ទៅក្របខណ្ឌការងារមួយទៀតឡើយ ។ នេះគឺជាអត្ថប្រយោជន៍ដ៏ធំធេងមួយ នៅពេលដែលមានការសន្យាជាមួយគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ អំពីកិច្ចការសមភាពយេនឌ័រ នៅក្នុងទសវត្សរ៍ ហើយដែលអ្នកតស៊ូមតិបានប្តេជ្ញាចិត្តចំពោះសន្ធិសញ្ញា CEDAW និងកិច្ចប្រជុំប៉េកាំង អាចយកទៅអនុវត្តបាន ដោយផ្ទាល់ ។ ខាងក្រោមនេះបង្ហាញពីជំហានសំខាន់ៗមួយចំនួន :

- **នាំអ្នកតស៊ូមតិផ្នែក CEDAW និងកិច្ចប្រជុំប៉េកាំងទៅកាន់តុពិភាក្សា**

  ការសរសេររបាយការណ៍គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ថ្នាក់ជាតិ ត្រូវតែភ្ជាប់នឹងការពិគ្រោះយោបល់ ជាមួយនឹងផ្នែកដែលជាប់ពាក់ព័ន្ធផ្សេងៗនៅក្នុងសង្គមអោយបានទូលំទូលាយ ។ ការស្វែងរកអ្នកជំនាញផ្នែក សមភាពយេនឌ័រ ដើម្បីផ្តល់ព័ត៌មាន ឬគំនិតនៅក្នុងរបាយការណ៍ ត្រូវតែចាប់ផ្តើមជាមួយសន្ធិសញ្ញា CEDAW និង កិច្ចប្រជុំប៉េកាំង ។ ការឆ្លងកាត់ស្ថាប័នរដ្ឋាភិបាលផ្សេងៗ រួមជាមួយអង្គការសង្គមស៊ីវិល និងអាចមានក្រុមមួយ ចំនួនដែលត្រូវចូលរួមយ៉ាងសកម្មនៅក្នុងការអនុវត្តន៍ និងការត្រួតពិនិត្យលើសន្ធិសញ្ញា CEDAW ហើយដាក់បញ្ចូលផែនការសកម្មភាពជាតិដែលធ្វើអោយកិច្ចប្រជុំទីក្រុងប៉េកាំងមានប្រសិទ្ធភាព ។




- **ធ្វើឲ្យរស់សន្ធិសញ្ញា CEDAW និងកិច្ចប្រជុំប៉េកាំងសំរាប់វិភាគស្ថានភាព**

ចំពោះគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍នីមួយៗរបាយការណ៍ភ្ជាប់ខ្សែជាមួយការវិភាគស្ថានភាព ដែលវាយតម្លៃទំហំការងារដើម្បីគោលដៅដែលបានសំរេច និងឧបសគ្គដែលគេជួបប្រទះ ។ ព័ត៌មានជាច្រើនទាក់ទងនឹង ការព្រួយបារម្ភអំពីសមភាពយេនឌ័រមិនត្រូវបានបង្កើត ឬប្រមូល ជាថ្មីទេ ពីព្រោះមានឯកសារគ្រប់គ្រាន់រួចហើយ នៅក្នុងរបាយការណ៍អង្គការមិនមែនរដ្ឋាភិបាល និងរដ្ឋាភិបាល ដែលបានផ្ញើទៅគណៈកម្មាធិការលុបបំបាត់ការរើសអើងលើស្ត្រីគ្រប់ទម្រង់ ជានៅក្នុងរបាយការណ៍ផ្សេងៗទៀត ដែលប្រហែលជាកំពុងរៀបចំនៅពេលដែលគេកំពុងព្រាងរបាយការណ៍គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ។ លើសពីនេះទៅទៀតការស្ទាបស្ទង់មតិនិងរបាយការណ៍ដែលទាក់ទងទៅនឹងស្ថានភាពសមភាពយេនឌ័រថ្នាក់ជាតិ ត្រូវបានរៀបចំសំរាប់កិច្ចប្រជុំប៉េកាំង+៥ និងកិច្ចប្រជុំប៉េកាំងបូក+១០ ។ របាយការណ៍ទាំងអស់នេះ រួមមានព័ត៌មាន និងស្ថិតិប្រកបដោយគុណភាពល្អពិតជាច្រើនស្តីអំពីសមភាព យេនឌ័រនៅក្នុងប្រទេស ។

- **ធ្វើឲ្យប្រាកដថារបាយការណ៍ឆ្លុះបញ្ចាំងពីការអនុវត្តសន្ធិសញ្ញា CEDAW និងកិច្ចប្រជុំប៉េកាំង**

ចំណុចដៅ និងសូចនាករជាសាកលប្រហែលជាចំណុចខ្សោយបំផុត នៃក្របខណ្ឌការងារក្នុងទស្សនៈវិស័យសមភាពយេនឌ័រ ហើយពិតជាអាចកែលំអបាន ។ កិច្ចការទាំងអស់នោះអាចកែតម្រូវ និងបន្ថែមបន្ថយ ដើម្បីឆ្លើយតបទៅនឹងបរិបទជាតិ នៅក្នុងរបាយការណ៍គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ។ សូចនាករសមភាព យេនឌ័រមួយចំនួនអាចបានតាក់តែងរួច ដើម្បីតាមដានការអនុវត្តន៍សន្ធិសញ្ញា CEDAW និងកិច្ចប្រជុំប៉េកាំងដែលជាគោលការណ៍ដែលមានប្រយោជន៍ ។ នៅពេលតាក់តែងសូចនាករថ្មី តម្រូវការកិច្ចប្រជុំប៉េកាំង និងសន្ធិសញ្ញា CEDAW ក៏ជា បន្ទាត់គោល ដើម្បីធានាថាសូចនាករទាំងអស់នោះត្រូវបានបង្កើតឡើងយ៉ាងសមស្រប សំរាប់ វាស់វែងការរីកចំរើន ក្នុងការសំរេចសមភាពយេនឌ័រ ។

## កែលំអសមត្ថភាពស្ថិតិស្តីអំពីបញ្ហាសមភាពយេនឌ័រ

គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ផ្តោតខ្លាំងស្រុះទៅលើការប្រើប្រាស់ទិន្នន័យស្ថិតិ ។ ចំណុចដៅ និង សូចនាករទាំងអស់មានគោលបំណងធ្វើយ៉ាងណាអាចវាស់វែងបានជាតួលេខ ដែលប្រើប្រាស់ទិន្នន័យដែលអាចប្រៀបធៀបបានរវាងប្រទេសនិងប្រទេស ឬតំបន់នឹងតំបន់ ។ មានករណីជាច្រើនដែលទិន្នន័យស្ថិតិស្តីអំពីបញ្ហាសមភាពយេនឌ័រដ៏សំខាន់បច្ចុប្បន្ននេះកំពុងខ្វះខាត ហើយការខិតខំប្រឹងប្រែងថ្នាក់ជាតិ ដើម្បីសំរេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ផ្តល់នូវឱកាសសំរាប់ការពង្រឹងសមត្ថភាពលើវិស័យទាំងអស់នេះ ។ លទ្ធភាពនៃការទទួលបាន ទិន្នន័យថ្មី និងកែលំអនោះ គឺជាការគាំទ្រតាមលំដាប់នូវការខិតខំប្រឹងប្រែងខាងតស៊ូមតិទាំងអស់ ដើម្បីលើកស្ទួយសមភាពយេនឌ័រនៅក្នុងប្រទេស ។

## កំណត់ការងារដែលលើកអាទិភាពដ៏សមស្រប

សន្ធិសញ្ញា CEDAW និងកិច្ចប្រជុំប៉េកាំងអាចលើកបញ្ជាក់ ដើម្បីកំណត់សកម្មភាពដែលត្រូវការបំផុត នៅក្នុងផ្នែកនីមួយៗ នៅក្នុងបរិបទនៃប្រទេសខុសៗគ្នា តាមគោលដៅនីមួយៗ ។ នៅក្នុងប្រទេសជាច្រើន ពិសេស ជាយុទ្ធសាស្ត្រនៃកិច្ចប្រជុំប៉េកាំងបានបំពេញបន្ថែមដោយផែនការសកម្មភាពថ្នាក់ជាតិ និងការពិនិត្យមើលឡើងវិញ ដែលបានធ្វើឡើងសំរាប់កិច្ចប្រជុំប៉េកាំង+៥ និងកិច្ចប្រជុំប៉េកាំង+១០ ។ នៅក្រោមសន្ធិសញ្ញា CEDAW មិនមានត្រឹមតែកាតព្វកិច្ច ដែលរដ្ឋាភិបាលទាំងអស់ត្រូវបំពេញតាមផ្លូវច្បាប់ប៉ុណ្ណោះទេ តែជំហានដែលត្រូវធ្វើក្នុងជីវិតប្រទេស ក្នុងការបំពេញតាមតំរូវការនៃអនុសញ្ញា មានលើកបញ្ជាក់នៅក្នុងយោបល់សរុបនៃគណៈកម្មាធិការ CEDAW នោះដែរ ។ លើសពីនេះទៅទៀត គណៈកម្មាធិការបានផ្តល់នូវមគ្គុទ្ទេសក៍យ៉ាងលំអិត អំពីបញ្ហាសំខាន់ជាច្រើន នៅក្នុងអនុសាសន៍ទូទៅរបស់ខ្លួន ដូចជាអំពើហិង្សាលើស្ត្រីភេទ ការថែរក្សាសុខភាព និងការចូលរួម ក្នុងឆាកនយោបាយ ។ ប្រភពទាំងអស់នេះអាចប្រើប្រាស់បានសំរាប់ការណែនាំជាបន្ថែមលើការវាស់វែង សមភាព យេនឌ័រជាក់លាក់ ដែលអាចអនុវត្តសំរេចបាននូវគោលដៅនីមួយៗ ។

## ការត្រួតពិនិត្យ : ត្រូវការផ្តោតយកចិត្តទុកដាក់លើសមភាពយេនឌ័រ

ការព្រាងរបាយការណ៍គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ថ្នាក់ជាតិ គឺជាជំហានទី១ក្នុងការផ្តួចផ្តើមដំណើរការត្រួតពិនិត្យ ដើម្បីធានាថា MDGs សំរេចការងារបាន ហើយរបាយការណ៍

ទាំងនេះ និងត្រូវស្ថិតក្រោមការ ពិនិត្យមើល និងកែសម្រួល តាមពេលវេលាដែលបានកំណត់ត្រឹមត្រូវ ។ ទោះបីជាយ៉ាងណា ក៏ហេតុការណ៍ នៃដំណើរការត្រួតពិនិត្យ រៀបចំយ៉ាងល្អ និងកើតមានពីរផ្សេងទៀត ផ្តល់ឱកាសអំណោយផល ដែលមានឥទ្ធិពលជាយុទ្ធសាស្ត្រថែមទៀត សំរាប់ការប្តេជ្ញាចិត្តចំពោះសមភាពយេនឌ័រ ក្នុងពេលកំពុង និងបន្តដំណើរសំរេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ។ ដោយប្រើប្រាស់ដំណើរការត្រួតពិនិត្យ និងដំណើការពិនិត្យសារឡើងវិញរបស់សន្ធិសញ្ញា CEDAW និងកិច្ចប្រជុំប៉េកាំង ដើម្បីទាញការយកចិត្តទុកដាក់ ចំពោះការរីកចំរើន ឧបសគ្គ និងការបរាជ័យក្នុងការអនុវត្តន៍វាស់វែងសមភាពយេនឌ័រ យោងតាម MDGs ករណីនេះអាចជួយធានាថា ការប្តេជ្ញាចិត្តក្របិតជាតិ និងអន្តរជាតិលើបំហិការងារយេនឌ័រ នៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍មិនចុះថយឡើយ ។

**សម័យប្រជុំ** CEDAW

រដ្ឋដែលជាភាគីលើអនុសញ្ញាចំនួន ១៧៥ ក្នុងខែតុលា ២០០៤ ត្រូវតែរាយការណ៍ទៅឱ្យគណៈកម្មាធិការ CEDAW រៀងរាល់៤ឆ្នាំម្តង ។ ក្នុងសម័យប្រជុំ២ដងរៀងរាល់ឆ្នាំរបស់ខ្លួន គណៈកម្មាធិការអនុវត្តជំនាញ របស់ខ្លួនដើម្បីពិនិត្យមើលរបាយការណ៍វាយតម្លៃការរីកចំរើន និងឧបសគ្គក្នុងការសំរេចនូវសមភាពយេនឌ័រ ដោយមានព័ត៌មានដែលអាចមានប្រយោជន៍ដែលហៅថា "របាយការណ៍ស្រមោល" អធិប្បាយអំពីស្ថានភាពប្រទេស ដែលស្នើឡើងដោយអង្គការស្ត្រីមិនមែនរដ្ឋាភិបាល (NGOs) ។ យោងតាមការពិនិត្យឡើងវិញដែលរួមបញ្ចូល ទាំងការពិភាក្សាជាមួយរដ្ឋាភិបាលផងនោះ គណៈកម្មាធិការ CEDAW បានផ្សព្វផ្សាយយោបល់សម្រេច ដោយកំណត់រកឃើញនូវគុណវិបត្តិ និងការខ្វះខាតដែលរដ្ឋាភិបាលគួរពិចារណារកវិធានការអនុវត្តទប់ទល់ ។

សន្ធិសញ្ញា CEDAWតំរូវអោយមានការលុបបំបាត់នូវគ្រប់រូបភាពនៃការរើសអើងលើជីវិតរបស់ស្ត្រីភេទ ក្នុងបំណងសំរេចបាននូវសមភាពយេនឌ័រ ។ ការផ្តួចផ្តើមគំនិតទាក់ទងនិងសមភាពយេនឌ័រដែលរដ្ឋាភិបាលមាន និងមិនមានបង្កើតឡើងដើម្បីសំរេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ក៏ដូចជាវិសាលភាពការងារចំពោះការផ្តួចផ្តើម ដែលបានទទួលការគាំទ្រដោយធនធានហិរញ្ញវត្ថុ និងយន្តការចាំបាច់សំរាប់ធ្វើអោយមានប្រសិទ្ធភាព ដូច្នេះ ហើយវាគឺជាការពិចារណាដ៏សំខាន់សំរាប់គណៈកម្មាធិការ ។ នៅពេលរាយការណ៍អំពីការរីកចំរើនរបស់គេ ក្នុងការអនុវត្តន៍

អនុសញ្ញានោះ រដ្ឋនានាគួរតែបញ្ចូលព័ត៌មានអំពីការវាស់វែងថ្មី ដែលណែនាំអោយប្រើប្រាស់ នៅក្នុង បរិបទនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ។ ហើយអង្គការមិនមែនរដ្ឋាភិបាលរបស់ស្ត្រីអាចនាំមកទាំងជោគជ័យ និងការលំបាក ដល់ការយកចិត្តទុកដាក់របស់គណៈកម្មាធិការ ។ កន្លែងណាដែលគណៈកម្មាធិការ CEDAW ផ្តល់ជំនួយនានាសំរាប់ការផ្តួចផ្តើមកែលំអគំនិតនៃសមភាពយេនឌ័រ តាមរយៈគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ការណែនាំអាចផ្តល់ឱ្យជាថ្មីនៅក្នុងដំណើរការពិនិត្យមើល MDG ឡើងវិញ ។

## កិច្ចប្រជុំប៉េកាំង+១០

សម័យប្រជុំលើកទី៤៩នៃគណៈកម្មាធិការដែលធ្វើឡើងនៅទីក្រុងប៉េកាំង ស្តីពីស្ថានភាពស្ត្រី នៅថ្ងៃទី ២៨ កុម្ភៈ ដល់ថ្ងៃទី ១១ មីនា ឆ្នាំ២០០៥ និងផ្តល់នូវឱកាសសំរាប់ការធ្វើសម្រង់ អំពីសមភាពយេនឌ័រដោយ អ្នកនយោបាយជាន់ខ្ពស់ក្នុងរដ្ឋាភិបាល ។ វានឹងចូលរួមនៅក្នុងការពិនិត្យមើលឡើងវិញនៃការរីកចំរើន និងការសំរេចនូវការតាំងចិត្ត ដែលបានធ្វើឡើងនៅកិច្ចប្រជុំប៉េកាំង និងការកំណត់នូវឧបសគ្គបច្ចុប្បន្ន និងយុទ្ធសាស្ត្រសមស្រប សំរាប់អនាគត ។ នៅក្នុងការត្រៀមលក្ខណៈ រដ្ឋាភិបាលនីមួយៗនឹងបានធ្វើការវាយតម្លៃផ្ទាល់ខ្លួន ចំពោះការរីកចំរើន ដោយផ្អែកលើតារាងសំណួររួម ហើយអង្គការសង្គមស៊ីវិលក៏មានឱកាសផ្តល់ព័ត៌មានជាមុន អំពីការរីកចំរើន និងឧបសគ្គ ។ ព័ត៌មានស្តីអំពីការរីកចំរើនកំរិតប្រទេស ដែលបានផ្តល់ជូននិងត្រូវប្រហាក់ប្រហែលគ្នាទៅជារបាយការណ៍សាកល ដែលនឹងបោះពុម្ពផ្សាយដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

ការចាត់ប្រមាណការរីកចំរើន និង ការជំនះផ្សេងៗ ក៏ដូចជាកិច្ចប្រជុំថ្នាក់តំបន់ដែលមានការរៀបចំ កិច្ចប្រជុំប៉េកាំង+១០ និងផ្តល់ព័ត៌មានទាក់ទងនឹងអនុសាសន៍ ដែលមានការព្រមព្រៀងដោយគណៈប្រតិភូ រដ្ឋាភិបាលទាំងនោះ ។ ជាលទ្ធផល អនុសាសន៍នៃកិច្ចប្រជុំប៉េកាំង +១០ និងលទ្ធផល នៅបន្ទាត់កិច្ចប្រជុំកំពូល សហស្សវត្សរ៍ +៥ (ធ្វើនៅខែកញ្ញាឆ្នាំ២០០៥) ដើម្បីផ្តល់ព័ត៌មានលើការពិភាក្សាអំពីមាតិកាឆ្ពោះទៅរកការសំរេចនូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ។

កិច្ចប្រជុំប៉េកាំង+១០ ផ្តល់ឱកាសដើម្បីពង្រឹង និងផ្តោតការយកចិត្តទុកដាក់លើ ចំណាត់ការងារនៃការឆ្លើយតបប្រឹងប្រែង អំពីសមភាពយេនឌ័រឆ្ពោះទៅសំរេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ។ ព័ត៌មានស្តីអំពីភាពគ្រប់គ្រាន់ នៃធនធានដែលមានស្រាប់ ដើម្បីលើកស្ទួយសមភាព

យេនឌ័រតាមរយៈគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ និងតំរោងសំណើ សំរាប់ការវាស់វែងដែលមានប្រសិទ្ធភាព ត្រូវតែបង្វែរទៅរកការយកចិត្តទុកដាក់របស់តំណាងរដ្ឋាភិបាល ។ អនុសាសន៍ដ៏សំខាន់នៃសមភាពយេនឌ័រ ដែលមានពីកិច្ចប្រជុំប៉េកាំង+១០ និងកិច្ចប្រជុំកំពូលសហស្សវត្សរ៍ និងជា ឧបករណ៍ដ៏មានឥទ្ធិពល សំរាប់ប្រើក្នុងកំរិតជាតិ ដើម្បីបង្កើនសកម្មភាពអោយកាន់តែប្រសើរឡើងទៅលើ សមភាពយេនឌ័រ ។

## ការបញ្ជ្រាបសមភាពយេនឌ័រ

ការប្រឹងប្រែងដើម្បីសំរេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ត្រូវមានការជួបប្រជុំគ្នាពីបណ្តាគ្រប់លំដាប់ថ្នាក់នៃរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានា ។ កិច្ចប្រជុំនេះផ្តល់ឱកាសដើម្បីពង្រឹងការសំរបសំរួល ស្តីអំពីការព្រួយបារម្ភអំពីសមភាពយេនឌ័រនិងលើកឡើងទៅដល់កម្រិតគោលនយោបាយថ្មី និងកាន់តែខ្ពស់ ។ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍និងចូលរួមជាវិភាគទានក្នុងការពង្រីកសមភាពយេនឌ័រ អោយទូលំទូលាយ និងពង្រឹងការត្រួតពិនិត្យ លើកស្ទួយការទទួលខុសត្រូវរបស់ភ្នាក់ងារតាមផ្នែក និងក្រសួងនានា ដែលទាក់ទងទៅនឹងចំណុចដៅនិងសូចនករជាក់លាក់ ។ ប្រសិនបើការពិចារណាអំពីសមភាពយេនឌ័រ បានបញ្ចូលទៅក្នុងការខិតខំប្រឹងប្រែងប្រកបដោយជោគជ័យ ដើម្បីសំរេចគោលដៅនោះ ដំណើរការ MDG នឹងជួយបំរើក្នុងការ ពង្រីកយេនឌ័រអោយបានទូលំទូលាយទូទាំងកម្មវិធីថ្នាក់ជាតិ និងគោលនយោបាយដែលមិនធ្លាប់មានពីមុនមក ។



សមភាពយេនឌ័រគឺជាការព្រួយបារម្ភ របស់គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ប៉ុន្តែត្រូវតែបង្ហាញអោយឃើញច្បាស់ក្នុងចំណុចដៅ សូចនករ និងយុទ្ធសាស្ត្រ ដើម្បីសម្រេចនូវទិសដៅនៅកំរិតជាតិ ។ ជាសំណាងល្អ សន្ធិសញ្ញា CEDAW និងកិច្ចប្រជុំប៉េកាំងផ្តល់មាតិកាដែលនាំពីត្រូវរាល់ពីចំណោទបញ្ហាសំខាន់ៗ ពេញលេញនៃបញ្ហាសមភាពយេនឌ័រដែលទាក់ទិន ហើយការណែនាំអោយច្បាស់លាស់ ដើម្បីសម្រេចតាមកម្មវិធីនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ។ ជំហានទី១ ក្នុងការធ្វើឱ្យសន្ធិសញ្ញា CEDAW និងកិច្ចប្រជុំប៉េកាំងមានប្រយោជន៍ សំរាប់គោលបំណងនេះ គឺត្រូវកំណត់វិធីជាក់លាក់ក្នុងក្របខណ្ឌការងារទាំងបីនេះឱ្យឆ្លើយតប និងគាំទ្រគ្នាទៅវិញទៅមក ។ អ្វីដែលលេចធ្លោ គឺការរៀបចំ ដែលការជាប់ទាក់ទងពីបញ្ហាសមភាពយេនឌ័រ ដែលបានលើកឡើងដោយគោលដៅ ទី១ និងគោលការណ៍ទាក់ទង រួមទាំងការប្តេជ្ញាចិត្តក្រោមសន្ធិសញ្ញា CEDAW និងកិច្ចប្រជុំប៉េកាំងបានផ្តល់ឱ្យ ។ តាមពិតទៅអាទិភាព ការព្រួយបារម្ភ និងការឆ្លើយតបដ៏សមស្របបំផុត អាចនិងខុសគ្នាពីតំបន់មួយទៅតំបន់មួយ និងពីប្រទេសមួយ ទៅប្រទេសមួយ ។ របាយការណ៍របស់គណៈកម្មាធិការ CEDAW សំរាប់ប្រទេសនីមួយៗ និងផែនការសកម្មភាព ថ្នាក់ជាតិ និងការពិនិត្យមើលឡើងវិញ ដែលបានធ្វើឡើងក្រោមកិច្ចប្រជុំប៉េកាំង គឺជា ឯកសារយោងសំខាន់ដែលមានឡើងសំរាប់ភ្ជាប់ទំនាក់ទំនងសន្ធិសញ្ញា CEDAW និងកិច្ចប្រជុំប៉េកាំងទៅក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ តាមរបៀបដែលប្រទេសនីមួយៗគ្នាអាចមើលឃើញពីតថភាព ។

# ផ្សារភ្ជាប់ទំនាក់ទំនង គោលដៅអភិវឌ្ឍន៍ សហស្សវត្សរ៍ ទៅនឹងសន្ធិសញ្ញា CEDAW និងកិច្ចប្រជុំប៉េកាំង



រូបភាពដោយ : អង្គការសិលការ



# លុបបំបាត់ភាពក្រីក្រ និងភាពអត់ឃ្លាន

ឧបសគ្គធំបំផុតដែលជួបប្រទះដោយប្រទេសជាង២១ ដែលព្យាយាមគេចចេញពីអន្ទាក់នៃភាពក្រីក្រ គឺការខ្វះខាតធនធានមនុស្សនិងសមត្ថភាព ដែលត្រូវការដើម្បីធ្វើការផ្លាស់ប្តូរចេញពីភាពក្រីក្រ និងវិសមភាពយេនឌ័រ ដែលជាកត្តាជំរុញដ៏សំខាន់បំផុតក្នុងការ ដោះស្រាយបញ្ហា ។ ករណីដែលស្ត្រីមិនបានទទួល ការអប់រំបឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សា ការមិនទទួលបានផលប្រយោជន៍សុខភាព និងសេវាសង្គម និងការមិនបានចូលរួមទីផ្សារកំលាំងពលកម្មពេញលេញ និងការចូលរួមទីផ្សារ កត្តាទាំងអស់ នេះធ្វើឱ្យស្ត្រីមិនមានលទ្ធភាពមានជំនាញ ចូលរួមការអភិវឌ្ឍន៍ដែលសេដ្ឋកិច្ចរបស់គេកំពុងត្រូវការយ៉ាងខ្លាំង ។ ខណៈពេលដែលក្រុមការងារសហស្សវត្សរ៍ ដោះស្រាយភាពក្រីក្រ គេបានកត់សំគាល់ឃើញថា “ របាំងមួយដ៏ធំបំផុត រាំងចំពោះស្ពានតភ្ជាប់ភាគច្រើន ប្រើប្រាស់ធនធានមនុស្ស គឺការបដិសេធចោលនូវសិទ្ធិមនុស្សជាមូលដ្ឋាន ដល់ប្រជាពលរដ្ឋ ហើយហេតុការណ៍នេះ កើតឡើងយ៉ាងខ្លាំងខ្លាយចំពោះស្ត្រី ”[៣] ។

ឱកាសរបស់ស្ត្រី ដែលត្រូវទទួលបានទ្រព្យធន និងធនធានផលិតបាននៅមានកំរិតនៅឡើយ ។ ឧទាហរណ៍ ភាគច្រើនលើសលប់នៃកសិករក្រីក្ររបស់ពិភពលោកគឺជាស្ត្រី ប៉ុន្តែនៅក្នុងប្រទេសជាច្រើនពួកគេមិនមានសិទ្ធិស្របច្បាប់កាន់កាប់កម្មសិទ្ធិដីធ្លី ដែលពួកគេកាប់ឆ្ការឬទ្រព្យធនដែលបង្កលក្ខណៈអោយពួកគេវិនិយោគលើដីធ្លីនោះទេ ។

ចំណុចដៅទី ១ :
កាត់បន្ថយត្រឹមពាក់កណ្តាល អត្រាប្រជាពលរដ្ឋ ដែលប្រកបរបរចិញ្ចឹមជីវិតបាន កំរៃ តិច ជាង ១ដុល្លារ ក្នុង ១ថ្ងៃ ។

ចំណុចដៅទី ២ :
កាត់បន្ថយត្រឹមពាក់កណ្តាល អត្រាប្រជាពលរដ្ឋដែលទទួលរងគ្រោះដោយភាពអត់ឃ្លាន ។



រូបភាពដោយ : អង្គការលីកាដូ




លើសពីនេះទៅទៀត បរាជ័យ ឬអសមត្ថភាពរបស់រដ្ឋាភិបាលទាំងឡាយ អំពីការផ្តល់ ហេដ្ឋារចនាសម្ព័ន្ធសង្គមគ្រប់គ្រាន់ បែរទៅជាបន្ទុកការងារចំពោះស្ត្រី និងនារីក្រីក្រក្មេងៗ យ៉ាងធំក្នុងការផ្តល់ការថែទាំ ។ ហើយយុគនៃភាពក្រីក្រ បណ្តាលមកពីការបន្ថែមម៉ោង ការងារប្រចាំថ្ងៃ ធ្វើអោយមានការខកខានចាប់យកឱកាស ក្នុងការរកប្រាក់ចំណូល ការចូលរួមនៅក្នុងកិច្ចការងារសហគមន៍ និងការទទួលការអប់រំ ។ ស្ត្រីក្រីក្រ ទាំងនៅក្នុងប្រទេសអភិវឌ្ឍន៍ និងកំពុងអភិវឌ្ឍន៍ ក៏អាចបំពោលយ៉ាងខ្លាំងដោយគោលនយោបាយពាណិជ្ជកម្មពិភពលោក ដែលមានឥទ្ធិពលដល់សេវាកម្មសំខាន់ៗត្រូវផ្តល់ក្នុងការបំពេញតម្រូវការទីផ្សារការងារ ទំនិញ និងសេវាកម្មនានា ។

ទាក់ទងទៅនឹងភាពអត់ឃ្លាន និងភាពខ្វះម្ហូបអាហារបំប៉ន ជាពិសេស វាមានសារៈសំខាន់ដែលទទួលស្គាល់ថាការលូតលាស់សេដ្ឋកិច្ចតែម្នាក់ឯង មិនមិនបានផ្តល់នូវដំណោះស្រាយទេ ប្រសិនបើលក្ខខណ្ឌសង្គម មិនស្មើភាពគ្នា និងការប្រតិបត្តិ ដែលប្រាសចាកពីសីលធម៌មនុស្សជាតិ បង្អាក់ដល់សិទ្ធិស្មើគ្នាក្នុងការទទួលបាន ស្បៀងអាហារ និងការថែរក្សាសុខភាពរបស់ស្ត្រី និងនារី ។ ការធានានូវស្វ័យភាពសេដ្ឋកិច្ច និងការផ្តល់អំណាច ចំពោះស្ត្រី មានសារៈសំខាន់ណាស់ ក្នុងការលើកស្ទួយតម្រូវការម្ហូបអាហារសំរាប់ខ្លួនគេ និងកូនរបស់គេ ។

**អ្វីដែល CEDAW និងកិច្ចប្រជុំប៉េកាំងលើកឡើង**

ក្រោមកិច្ចព្រមព្រៀងសន្ធិសញ្ញា CEDAW រដ្ឋាភិបាលទាំងឡាយត្រូវទទួលភារកិច្ច និងប្តេជ្ញាចិត្តតាមកិច្ចប្រជុំប៉េកាំង ដើម្បីធានាថាមានការចូលទូលាយក្នុងការធានាសិទ្ធិស្ត្រី និងផ្តល់ឱកាសឱ្យទទួលបានធនធាន សេដ្ឋកិច្ចចាំបាច់យ៉ាងសំខាន់ សំរាប់កាត់បន្ថយភាពក្រីក្រ ។ រដ្ឋាភិបាលទាំងនោះត្រូវតែធានាសមភាពយេនឌ័រ លើគ្រប់វិស័យនៃការងារ ។ ច្បាប់ គោលនយោបាយ និងដំណើរការរដ្ឋបាល ត្រូវតែធានាថាស្ត្រីមានសិទ្ធិស្មើគ្នាទាក់ទងនឹងទ្រព្យសម្បត្តិ កិច្ចសន្យានិងប្រាក់កម្ចី នៅក្នុងជីវិតសេដ្ឋកិច្ចសាធារណៈ និងក្នុងបរិបទអាពាហ៍ពិពាហ៍ និង ជីវិតគ្រួសារ ។ ស្ត្រីត្រូវតែបានផ្តល់សិទ្ធិទទួលនូវទីផ្សារលក់ដូរ ឥណទាន និង បច្ចេកវិទ្យា ។ ការផ្តោតការយកចិត្តទុកដាក់ ត្រូវតែសង្កត់ធ្ងន់ទៅលើស្ថានភាពស្ត្រីនៅតាមជនបទ និងជាពិសេសសិទ្ធិស្មើគ្នារបស់គេចំពោះកម្មសិទ្ធិដីធ្លី ដោយត្រូវតែធានាអោយបានទាំងស្ថានភាពរស់នៅពេញលេញទាក់ទងនឹងផ្ទះសំបែង អនាម័យ និងការផ្គត់ផ្គង់ទឹក ។



# និងភាពអត់ឃ្លាន

គោលដៅទី ១

## CEDAW

- លុបបំបាត់ការរើសអើងលើស្ត្រីភេទ ដើម្បីធានាសិទ្ធិដូចគ្នាចំពោះបុរស និងស្ត្រីនៅក្នុងការងារ (មាត្រា ១១)
- ជាពិសេស ធានានូវឱកាសការងារដូចគ្នា មានជំរើសវិជ្ជាជីវៈដោយសេរី ផលប្រយោជន៍និងលក្ខខណ្ឌសេវាកម្ម ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងទទួលបានប្រាក់ខែដូចគ្នាលើតម្លៃការងារដូចគ្នា (មាត្រា១១.២ ១១.៥ ១១.៨)
- ធានាសមភាពរវាងបុរស និងស្ត្រីចំពោះមុខច្បាប់និងជាពិសេសសិទ្ធិស្របច្បាប់ដូចគ្នានិងសមត្ថភាពទាក់ទង នឹងកិច្ចសន្យា និងទ្រព្យសម្បត្តិ (មាត្រា១៥)
- ធានានូវសមភាពរវាងបុរស និងស្ត្រីលើគ្រប់វិស័យទាំងផ្នែកសេដ្ឋកិច្ច និងជីវិតសង្គមនិងជាពិសេសសិទ្ធិដូចគ្នាចំពោះកម្ចីធនាគារ និងរាល់ទំរង់នៃឥណទានហិរញ្ញវត្ថុ (មាត្រា១៣ .២ )
- ធានាសមភាពរវាងបុរស និងស្ត្រីក្នុងអាពាហ៍ពិពាហ៍ និងជីវិតគ្រួសារជាពិសេសសិទ្ធិស្មើគ្នាសំរាប់ប្តី ប្រពន្ធទាក់ទងនឹងភាពជាម្ចាស់ទ្រព្យធនដែលរកបាន ការគ្រប់គ្រង ការងាររដ្ឋបាល ការកំសាន្ត និងការបែកចាយទ្រព្យសម្បត្តិ (មាត្រា១៦.១h)
- ធានាថាស្ត្រីជនបទនូវការប្រព្រឹត្តស្មើគ្នានៅក្នុងការកែទំរង់ដីធ្លី និងឱកាសទទួលឥណទាន និងប្រាក់កម្ចីកសិកម្ម គ្រឿងប្រដាប់សំរាប់ទីផ្សារ និងបច្ចេកវិទ្យា

## វេទិកាប៉េកាំង សំរាប់សកម្មភាព

- ពិនិត្យមើលឡើងវិញនូវច្បាប់ និងការអនុវត្តទំលាប់ដើម្បីធានាសិទ្ធិស្មើគ្នារបស់ស្ត្រី និងឱកាសទទួលនូវធនធានសេដ្ឋកិច្ច (ទិសដៅយុទ្ធសាស្ត្រ A.2)
- ផ្តល់ឱ្យស្ត្រីទទួលនូវការសន្សំប្រាក់ យន្តការឥណទាន និងការបង្កើតស្ថាប័នក្នុងវិស័យនេះ (ទិសដៅយុទ្ធសាស្ត្រ A.3)
- អភិវឌ្ឍវិធីសាស្ត្រផ្នែកយេនឌ័រ និងធ្វើការស្រាវជ្រាវដើម្បីដោះស្រាយភាពក្រីក្ររបស់ស្ត្រី (ទិសដៅយុទ្ធសាស្ត្រ A.4)
- លើកស្ទួយនូវសិទ្ធិសេដ្ឋកិច្ច និងឯករាជភាពរបស់ស្ត្រី រួមទាំងឱកាសទទួលការងារ លក្ខខណ្ឌការងារសមរម្យ និងការគ្រប់គ្រងលើធនធានសេដ្ឋកិច្ច (ទិសដៅយុទ្ធសាស្ត្រ F.1)
- សំរួលដល់ឱកាសស្មើគ្នារបស់ស្ត្រីក្នុងការទទួលនូវធនធាន ការងារទីផ្សារ និងពាណិជ្ជកម្ម (ទិសដៅយុទ្ធសាស្ត្រ F.2)
- ផ្តល់សេវាកម្មជំនួញ ការបណ្តុះបណ្តាលនិងឱកាសលើទីផ្សារ ព័ត៌មាននិងបច្ចេកវិទ្យាជាពិសេសចំពោះស្ត្រី ដែលមានប្រាក់ចំណូលទាប (ទិសដៅយុទ្ធសាស្ត្រ F.3)

# លុបបំបាត់ភាពក្រីក្រ

(មាត្រា១៤.២.g)

- ធានាដល់ស្ត្រីជនបទអោយបានភាពរីករាយ ក្នុងស្ថានភាពរស់នៅពេញលេញ ជាពិសេសទាក់ទងនឹងផ្ទះសំបែង អនាម័យ អគ្គិសនី និងការផ្គត់ផ្គង់ទឹក ព្រមទាំងការដឹកជញ្ជូននិងគមនាគមន៍ (មាត្រា ១៤.២.h)

- ពង្រឹងសមត្ថភាពសេដ្ឋកិច្ច និងបណ្តាញពាណិជ្ជកម្មរបស់ស្ត្រី (ទិសដៅយុទ្ធសាស្ត្រ.F.4)
- លុបបំបាត់រាល់ការបែងចែកវណ្ណៈក្នុងការងារ និងការរើសអើងការងារគ្រប់រូបភាព (ទិសដៅយុទ្ធសាស្ត្រ.F.5)
- លើកកម្ពស់ភាពសុខដុមរមនានៃការងារ និងការទទួលខុសត្រូវចំពោះគ្រួសារស្ត្រី និងបុរស (ទិសដៅ យុទ្ធសាស្ត្រ.F.6)



# និងភាពអត់ឃ្លាន

គោលដៅ ទី ១




រូបភាពដោយ : អង្គការសិលការ



# សម្រេចនូវការអប់រំ បឋមសិក្សាជាសាកល

គោលដៅនៃការអប់រំមានបំណងធានាថា ត្រឹមឆ្នាំ២០១៥ កុមារា និងកុមារីម្នាក់ៗបញ្ចប់ការសិក្សានៅថ្នាក់បឋមសិក្សាឱ្យបានទាំងស្រុង ។ នៅពេលមានចលនាច្បាស់លាស់ ដើម្បីសំរេចសមភាពយេនឌ័រនៅក្នុងការអប់រំ ជាងពីរបីទសវត្សរ៍កន្លងមកនេះ វានៅតែមិនទាន់សំរេចបានទាំងស្រុងក្នុងចំណោមកុមារ១៥០លាននាក់ ដែលមាន អាយុពី៦-១១ឆ្នាំ ហើយដែលបច្ចុប្បន្ននេះមិនបានចូលសាលា ។ ជាង៩០លាននាក់ជាកុមារី ហើយនៅតំបន់ ខ្លះទៀត ការចុះឈ្មោះចូលរៀននៅថ្នាក់បឋមសិក្សារបស់កុមារី នៅមានកំរិតទាបជាង៦០ភាគរយ ។

ចំណុចដៅទី៣ :
ធានាថាកុមារា និងកុមារីទាំងអស់បញ្ចប់វគ្គសិក្សានៅថ្នាក់បឋមសិក្សាដោយពេញលេញ

របាំងសេដ្ឋកិច្ច សង្គម និងវប្បធម៌ជាច្រើន ត្រូវតែលើកឡើង ដើម្បីសំរេចនូវសមភាពយេនឌ័រក្នុងការអប់រំ នៅថ្នាក់បឋមសិក្សា រួមទាំងតំរូវការការងាររបស់កុមារីនៅផ្ទះ នៅកសិដ្ឋាន ព្រមទាំងភាពជាក់ស្តែងដែលថា ឃើញថាការងាររបស់ពួកគេ នឹងមានឱកាសទទួលបានប្រាក់ចំណូល ដែលនឹងត្រូវកំណត់ នៅពេលពេញវ័យ ហើយត្រូវទុកឱ្យធ្វើការមើលថែបងប្អូនតូចៗ ដែលរកឃើញ និងកំពុងតែកាត់បន្ថយឱកាស ហើយប៉ះពាល់ដល់ក្មេងស្រីដែលត្រូវការការរៀនសូត្រ ។ការកាត់បន្ថយតម្លៃចូលរៀន (ដូចជាថ្លៃសាលា សំលៀកបំពាក់ឯកសណ្ឋាន និងតម្លៃសៀវភៅសិក្សា) ត្រូវបានបង្ហាញអោយឃើញពីផលប៉ះពាល់សំខាន់ៗមួយចំនោះ ការចូលរៀន

២






របស់កុមារី ស្របជាមួយនឹងការដោះស្រាយការព្រួយបារម្ភរបស់ឪពុកម្តាយអំពីសេចក្តីសុខ និងសុវត្ថិភាព តាមរយៈការបណ្តុះបណ្តាល ការជួលគ្រូស្រីបន្ថែមទៀត និងការបង្កើនឱកាសទទួលនូវបង្គន់អនាម័យ ។ ការបង្ហាញ ពីអំពើហិង្សាទាក់ទងនឹងយេនឌ័រលើកុមារី នៅក្នុងមជ្ឈដ្ឋានសិក្សា ព្រមទាំងនៅពេលធ្វើដំណើរ ទៅមកទាក់ទង និងសាលារៀន ត្រូវតែដោះស្រាយជាបន្ទាន់ ។

## អ្វីដែល CEDAW និងប៉េកាំងតម្រូវឱ្យធ្វើ

សន្ធិសញ្ញា CEDAW និងកិច្ចប្រជុំប៉េកាំង តម្រូវអោយរដ្ឋាភិបាលធ្វើការប្តេជ្ញាចិត្តដើម្បីធានាសមភាព យេនឌ័រ គ្រប់កំរិតនៃការអប់រំនៅថ្នាក់បឋមសិក្សា អនុវិទ្យាល័យ និងសាកលវិទ្យាល័យ ព្រមទាំងក្នុងការ បណ្តុះបណ្តាលបច្ចេកទេស ការបន្តការសិក្សា និងកម្មវិធីអក្ខរកម្ម ។ បញ្ហានេះមិនត្រឹមតែទាក់ទង នឹងការផ្តល់ ឱកាសស្មើគ្នាក្នុងការចូលរៀនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធានាវិធានការដែលចាំបាច់គ្រប់បែបយ៉ាងដើម្បីធានាថាកុមារីនិងស្ត្រី ត្រូវបានគាំទ្រឱ្យមានលទ្ធភាពបំពេញការសិក្សាស្មើគ្នាដូចកុមារា និងបុរសដែរ ។ រដ្ឋាភិបាល ត្រូវតែក្តាប់ អោយបាននូវឧបសគ្គសំខាន់ៗដែលរារាំងមិនអោយកុមារី និងស្ត្រី ទទួលបាននូវការអប់រំ និងលើក យកមកពិភាក្សា ពង្រីកការដោះស្រាយ ជំនះលើឧបសគ្គទាំងនោះ ។



# បឋមសិក្សាជាសាកល

គោលដៅ ២

## CEDAW

- លុបបំបាត់ការរើសអើងលើស្ត្រីភេទ ដើម្បីធានាសិទ្ធិស្មើគ្នាជាមួយបុរស និងស្ត្រីក្នុងការអប់រំ (មាត្រា១០)
- ជាពិសេស ធានានូវឱកាសដូចគ្នាចំពោះការសិក្សា និងការទទួលសញ្ញាប័ត្រនៅគ្រប់កំរិតនៃការអប់រំ នៅក្នុង តំបន់ជនបទ និងទីក្រុងដូច ជាមានឱកាសទទួលបានស្តង់ដារអប់រំដូចគ្នា លុបបំបាត់ការសិក្សាដែល មានលក្ខណៈមិនត្រឹមត្រូវ ឱកាសទទួលបាននូវអាហារូបករណ៍ និងជំនួយដូចគ្នា ឱកាសទទួលបានការបន្តការអប់រំ និងកម្មវិធីអក្ខរកម្មដូចគ្នា ។ ការកាត់បន្ថយអត្រាឈប់រៀនរបស់សិស្សស្រី បង្កើតឱ្យមានកម្មវិធីនានា សំរាប់កុមារី និងស្ត្រីដែលបោះបង់សាលាមុនពេលកំណត់ (មាត្រា១០.a, b, c, d, e, និង f)
- ធានាសិទ្ធិស្ត្រីនៅតំបន់ជាប់ស្រុកាល អោយទទួលបានរាល់ប្រភេទនៃការបណ្តុះបណ្តាល និងការអប់រំ(មាត្រា១៤.២. d)
- ចាត់វិធានការច្បាប់ និងវិធានការផ្សេងៗដែលចាំបាច់ ដើម្បីផ្តល់នូវការការពារប្រកបដោយប្រសិទ្ធភាព ប្រឆាំងនឹងអំពើហិង្សាយេនឌ័រ (អនុសាសន៍ទូទៅលេខ១៩)

## វេទិការប៉េកាំងសំរាប់ប្រតិបត្តិ

- ធានាឱកាសទទួលបានការអប់រំស្មើគ្នា (មើលទៅយុទ្ធសាស្ត្រB.1)
- លុបបំបាត់ការរើសអើងលើក្មេងស្រីក្នុងការអប់រំ ពង្រីកជំនាញ និងការបណ្តុះបណ្តាល (មើលទៅយុទ្ធសាស្ត្រL.4)
- អភិវឌ្ឍការអប់រំ និងការបណ្តុះបណ្តាលដែលគ្មានការរើសអើង (មើលទៅយុទ្ធសាស្ត្រB.4)
- ស្វែងរក ការគាំទ្រថវិកាធនធានអោយបានគ្រប់គ្រាន់សំរាប់ត្រួតពិនិត្យ ការអនុវត្តនៃកំណែទំរង់វិស័យអប់រំ (មើលទៅយុទ្ធសាស្ត្រB.5)
- លុបបំបាត់អំពើហិង្សាលើកុមារី (មើលទៅយុទ្ធសាស្ត្រL.7)

# លើកកម្ពស់សមភាពយេនឌ័រនិងផ្តល់អំណាចដល់ស្ត្រី

ចំណុចគោលដៅទី ៤ : លុបបំបាត់ភាពខុសគ្នាផ្នែកយេនឌ័រនៅក្នុងការអប់រំថ្នាក់បឋមសិក្សានិងអនុវិទ្យាល័យត្រឹមឆ្នាំ២០០៥ និងនៅគ្រប់កំរិតនៃការអប់រំទាំងអស់មិនអោយលើសពីឆ្នាំ២០១៥ ។

វិធានការពេញលេញដែលត្រូវតែធ្វើ ដើម្បីសំរេចបាននូវសមភាពយេនឌ័រ និងការផ្តល់អំណាចដល់ស្ត្រី បានបង្កើតជាគំរោងយ៉ាងទូលំទូលាយរួចហើយនៅក្នុងសន្ធិសញ្ញា CEDAW និងកិច្ចប្រជុំប៉េកាំងសំរាប់ប្រតិបត្តិការ ក៏ដូចជាមាននៅក្នុងវាក្យខណ្ឌសំខាន់ៗនៃមហាសន្និបាតអន្តរជាតិដទៃទៀតនិងឯកសារសន្និសីទនានា ។ ទិសដៅដែលបានផ្តល់ដល់រដ្ឋាភិបាលនៅក្នុងឯកសារទាំងអស់នោះ ជាប់ពាក់ព័ន្ធទៅនឹងវិសាលភាពដ៏សំខាន់បំផុតនៃវិសមភាពយេនឌ័រ លើគ្រប់ផ្នែកនៃជីវិតរបស់ស្ត្រី រួមមានទំនាក់ទំនងស្តីអំពីអំពើហិង្សាដោយសារយេនឌ័រ វប្បធម៌ដែលមាន លក្ខណៈមិនប្រោស ប្រៃវែបន្តំគំនិត ការជួញដូរស្ត្រីនិងអំពើពេស្យាចារ ជំលោះប្រដាប់អាវុធ នាកជីវិតនយោបាយ ច្បាប់និងឋានៈស្របច្បាប់ រចនាសម្ព័ន្ធរបស់រដ្ឋាភិបាល ប្រព័ន្ធផ្សព្វផ្សាយ ការអប់រំ ការផ្តល់ការងារ ការថែរក្សាសុខភាព ការធ្វើផែនការគ្រួសារ បរិស្ថាន ជីវភាពនៅតាមជនបទ អាពាហ៍ពិពាហ៍ និងទំនាក់ទំនងគ្រួសារ ។ ដូចនេះគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ត្រូវបានបង្កើតឡើងដំបូងជាមធ្យោបាយនៃការបង្កើនល្បឿន និងការកែលម្អកិច្ចខិតខំប្រឹងប្រែងឡើងវិញ ដើម្បីបំពេញការប្តេជ្ញាចិត្តជាសកលដែលមានស្រាប់ និងសេចក្តីប្រកាសសហស្សវត្សរ៍ដែល ផ្តោតជាពិសេសទៅលើការពង្រឹងការអនុវត្តន៍សន្ធិសញ្ញា CEDAW ដែលជាកិច្ចការបន្ទាន់បំផុតត្រូវធ្វើឡើង




នៅក្នុងគោលដៅទី៣ គឺត្រូវអនុវត្តសន្ធិសញ្ញា CEDAW និងកិច្ចប្រជុំប៉េកាំងនៅគ្រប់លំដាប់ថ្នាក់ ។ សារៈសំខាន់នៃដំណើរការធ្វើឱ្យមានការយល់ដឹងទូលំទូលាយ ប្រសើរជាងការយល់តែម្នាក់ៗ ហើយកម្មវិធីជំរុញសមភាពយេនឌ័រតែងមានច្បាស់លាស់ ក្នុងបរិបទនៃគោលដៅសហស្សវត្សរ៍ ។ បញ្ហាសមភាពយេនឌ័រដែល កើតចេញពីការបារម្ភភ្ជាប់ៗជាងគេ ក្រោមគោលដៅខុសៗគ្នា មិនអាចមានប្រសិទ្ធភាពបានលុះត្រាណាតែសកម្មភាពទាំងនោះត្រូវដាក់ជូនដល់ភាគីអនុវត្តជួរមុខធំរុះ ។ ជាឧទាហរណ៍ ការប្រឹងប្រែងដើម្បីកែលំអចំណូល របស់ស្ត្រី មិនអាចផ្តោតដាច់ដោយឡែកតែទៅលើច្បាប់ និងគោលនយោបាយទាក់ទងចំពោះកន្លែងធ្វើការ និង ទីផ្សារប៉ុណ្ណោះទេ ។ វាត្រូវតែផ្តោតផងដែរ ទៅលើបញ្ហានៃវិសមភាពយេនឌ័រ ដែលកើតចេញពីការ អប់រំសំរាប់ស្ត្រី ទៅលើ សមត្ថភាពស្របច្បាប់ ទៅលើហិង្សាចំពោះស្ត្រី ទៅលើផ្តត់គំនិតបែបវប្បធម៌ ទៅលើការបែងចែក ការងារតាមរបៀបយេនឌ័រនៅក្នុងក្រុមគ្រួសារ ក៏ដូចជាទៅលើបញ្ហាទូលំទូលាយ នៃគោលនយោបាយ ម៉ាក្រូសេដ្ឋកិច្ច និងការបែងចែកធនធានរួម ។ការប្រឹងប្រែងរួមគ្នាដើម្បីលើកកម្ពស់ការអនុវត្តន៍សន្ធិសញ្ញា CEDAW និងកិច្ចប្រជុំប៉េកាំង ក្នុងចំណោមការងារទាំងអស់គឺជាការចាំបាច់ប្រសើរដែល នៅឆ្នាំ២០១៥ មកដល់នោះសភាពការណ៍នឹងអាចមានការផ្លាស់ប្តូរពិតប្រាកដសំរាប់ស្ត្រី ហើយភាពរីកចំរើនគួរកត់សម្គាល់នឹងអាចមានមិនត្រឹមតែចំពោះគោលដៅទី៣ប៉ុណ្ណោះទេ តែក៏អាចមានចំពោះគោលដៅទាំងអស់នោះផងដែរ ។

## ផ្លូវដែល CEDAW និងកិច្ចប្រជុំប៉េកាំងជួយស្ត្រី

បន្ថែមទៅលើការស្វែងរកការគាំទ្រ សំរាប់បង្កើនការប្រឹងប្រែង ដើម្បីអនុវត្តនូវរាល់គំរោងការអនាគត ទាំងអស់របស់សន្ធិសញ្ញា CEDAW និងកិច្ចប្រជុំប៉េកាំង ការយកចិត្តទុកដាក់គួរតែត្រូវបានផ្តោតទៅលើ គំរោងការអនាគត ជាក់លាក់ក្នុងគោលដៅនីមួយៗ ដែលជាប់ទាក់ទងជាមួយនឹងការបង្កើតហេដ្ឋារចនាសម្ព័ន្ធ ហើយនិងមានលទ្ធភាពបង្កបរិយាកាស ដែលត្រូវការសំរាប់ការយល់ដឹងអំពីសិទ្ធិមនុស្សរបស់ស្ត្រី ។ ពេលដែល មូលដ្ឋានសំខាន់នេះ មិនបានបង្កើតឱ្យមានឡើងទេនោះ កិច្ចខិតខំប្រឹងប្រែង ដើម្បីអោយមានសមភាពយេនឌ័រ និង ជួបប្រទះនូវឧបសគ្គជាមិនខាន ។ កំណត់សំគាល់សំខាន់ៗ គឺជាតំរូវការសំរាប់ការពិនិត្យមើលឡើងវិញនូវច្បាប់ រដ្ឋធម្មនុញ្ញ និងការផ្លាស់ប្តូរ ហើយឱ្យមានការបង្កើតរចនាសម្ព័ន្ធ



សេចក្ដីប្រកាសសហស្សវត្សរ៍ និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (MDGs) បានបើកច្រកថ្មី សំរាប់ឈានឆ្ពោះទៅមុខនៃសមភាពយេនឌ័រ ។ គោលដៅទាំងនេះ ដែលធ្លាប់ជាសក្ដានុពលដ៏ប្រសើរនោះ អាចជាមធ្យោបាយ ដែលតាមរយៈនេះការចំណាក់ចំណងរវាងវិសមភាពយេនឌ័រ ការមិនយកចិត្តទុកដាក់ ការបន្ថោកបន្ទាបសក្ដានុពលមនុស្សជាស្ត្រី និងការចេះតែបន្តវិលវល់ភាពក្រីក្រ ត្រូវបានគេផ្ដោតយកចិត្តទុកដាក់ ហើយជាចុងក្រោយទទួលបានជោគជ័យ ។

ខ្លឹមសារមាគ៌ាឆ្ពោះទៅរកសមភាពយេនឌ័រ អនុសញ្ញាស្ដីអំពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងចំពោះស្ត្រី និងសន្និសីទពិភពលោកលើកទី៤នៅទីក្រុងប៉េកាំងស្ដីអំពីស្ត្រី ត្រូវតែជាគំរូរបស់យើងសំរាប់សម្រេចសក្ដានុពលដែលបានកំណត់ដោយគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ។ភាពយល់ដឹងគ្រប់ជ្រុងជ្រោយ និងបទពិសោធន៍អំពីលក្ខណៈយេនឌ័រនៃការរើសអើង និងជំហានចាំបាច់ដើម្បីសម្រេចសមភាពយេនឌ័រដែលបានបង្កើតឡើងតាមរយៈ CEDAW និងសន្និសីទក្រុងប៉េកាំង ដែលយើងអាចយកមកប្រើប្រាស់បាន ។ ដោយប្រើខ្លឹមសារ CEDAW និងសន្និសីទប៉េកាំងជាមូលដ្ឋាន ដើម្បីឆ្លុះបញ្ចាំងឱ្យជ្រួតជ្រាប និងដោះស្រាយ ពីទិដ្ឋភាពសមភាពយេនឌ័រនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ និងការអនុវត្តន៍ រួមទាំងការប្ដេជ្ញាជឿជាក់ និងប្រសិទ្ធភាពនៃការអភិវឌ្ឍន៍ អាចដាក់រួមគ្នាប្រកបដោយឥទ្ធិពលខ្លាំងក្លា ។

SILAKA



# លើកស្ទួយសមភាពយេនឌ័រ

នៅក្នុងគោលដៅទី៣ គឺត្រូវអនុវត្តសន្ធិសញ្ញា CEDAW និងកិច្ចប្រជុំប៉េកាំងនៅគ្រប់លំដាប់ថ្នាក់ ។ សារៈសំខាន់នៃដំណើរការធ្វើឱ្យមានការយល់ដឹងទូលំទូលាយ ប្រសើរជាងការយល់តែម្នាក់ៗ ហើយកម្មវិធីជំរុញសមភាពយេនឌ័រតែងមានច្បាស់លាស់ ក្នុងបរិបទនៃគោលដៅសហស្សវត្សរ៍ ។ បញ្ហាសមភាពយេនឌ័រដែល កើតចេញពីការបារម្ភភ្ជាប់ៗជាងគេ ក្រោមគោលដៅខុសៗគ្នា មិនអាចមានប្រសិទ្ធភាពបានលុះត្រាណាតែសកម្មភាពទាំងនោះត្រូវដាក់ជូនដល់ភាគីអនុវត្តជួរមុខចំរុះ ។ ជាឧទាហរណ៍ ការប្រឹងប្រែងដើម្បីកែលំអចំណូល របស់ស្ត្រី មិនអាចផ្តោតដាច់ដោយឡែកតែទៅលើច្បាប់ និងគោលនយោបាយទាក់ទងចំពោះកន្លែងធ្វើការ និង ទីផ្សារប៉ុណ្ណោះទេ ។ វាត្រូវតែផ្តោតផងដែរ ទៅលើបញ្ហានៃវិសមភាពយេនឌ័រ ដែលកើតចេញពីការ អប់រំសំរាប់ស្ត្រី ទៅលើ សមត្ថភាពស្របច្បាប់ ទៅលើហិង្សាចំពោះស្ត្រី ទៅលើផ្លូវគំនិតបែបវប្បធម៌ ទៅលើការបែងចែក ការងារតាមរបៀបយេនឌ័រនៅក្នុងក្រុមគ្រួសារ ក៏ដូចជាទៅលើបញ្ហាទូលំទូលាយ នៃគោលនយោបាយ ម៉ាក្រូសេដ្ឋកិច្ច និងការបែងចែកធនធានរួម ។ ការប្រឹងប្រែងរួមគ្នាដើម្បីលើកកម្ពស់ការអនុវត្តន៍សន្ធិសញ្ញា CEDAW និងកិច្ចប្រជុំប៉េកាំង ក្នុងដំណើរការងារទាំងអស់គឺជាការធានាដ៏ប្រសើរដែល នៅឆ្នាំ២០១៥ មកដល់នោះសភាពការណ៍នឹងអាចមានការផ្លាស់ប្តូរពិតប្រាកដសំរាប់ស្ត្រី ហើយភាពរីកចំរើនគួរកត់សម្គាល់នឹងអាចមានមិនត្រឹមតែចំពោះគោលដៅទី៣ប៉ុណ្ណោះទេ តែក៏អាចមានចំពោះគោលដៅទាំងអស់នោះផងដែរ ។

## អ្វីដែល CEDAW និងកិច្ចប្រជុំប៉េកាំងតម្រូវឱ្យធ្វើ

បន្ថែមទៅលើការស្វែងរកការគាំទ្រ សំរាប់បង្កើនការប្រឹងប្រែង ដើម្បីអនុវត្តនូវរាល់គំរោងការអនាគត ទាំងអស់របស់សន្ធិសញ្ញា CEDAW និងកិច្ចប្រជុំប៉េកាំង ការយកចិត្តទុកដាក់គួរតែត្រូវបានផ្តោតទៅលើ គំរោងការអនាគត ជាក់លាក់ក្នុងគោលដៅនីមួយៗ ដែលជាប់ទាក់ទងជាមួយនឹងការបង្កើតហេដ្ឋារចនាសម្ព័ន្ធ ហើយនិងមានលទ្ធភាពបង្កបរិយាកាស ដែលត្រូវការសំរាប់ការយល់ដឹងអំពីសិទ្ធិមនុស្សរបស់ស្ត្រី ។ ពេលដែល មូលដ្ឋានសំខាន់នេះ មិនបានបង្កើតឱ្យមានឡើងទេនោះ កិច្ចខិតខំប្រឹងប្រែង ដើម្បីអោយមានសមភាពយេនឌ័រ និង ជួបប្រទះនូវឧបសគ្គជាមិនខាន ។ កំណត់សំគាល់សំខាន់ៗ គឺជាតំរូវការសំរាប់ការពិនិត្យមើលឡើងវិញនូវច្បាប់ រដ្ឋធម្មនុញ្ញ និងការផ្លាស់ប្តូរ ហើយឱ្យមានការបង្កើតរចនាសម្ព័ន្ធ

# និងផ្តល់អំណាចដល់ស្ត្រី

សមស្រប ដោយមានដំណើរការក្នុងរដ្ឋាភិបាល ដែលរួមទាំងការបង្កើត និងការពង្រឹងយន្តការដឹកនាំរបស់ស្ត្រី ។ លើសពីនេះទៅទៀត នៅពេលដែលរដ្ឋាភិបាល ជាច្រើនបានបង្ហាញនូវឆន្ទៈកាន់តែល្អប្រសើរឡើង ដើម្បីបង្កើតច្បាប់ដែលចាំបាច់ និងកែលំអរចនាសម្ព័ន្ធ ការទទួលស្គាល់ដោយមានការផ្លាស់ប្តូរទាំងនេះ ត្រូវតែមានធនធាន និងមូលនិធិអោយបានគ្រប់គ្រាន់ ក្នុងគោលបំណង ធ្វើអោយមានប្រសិទ្ធភាព កុំអោយមានការខ្វះខាតយ៉ាងខ្លាំងដូចពីមុន ។



# លើកស្ទួយសមភាពយេនឌ័រ

## CEDAW

- តំណាងអោយគោលការណ៍នៃសមភាពរបស់បុរស និងស្ត្រីនៅក្នុងរដ្ឋធម្មនុញ្ញជាតិ ( មាត្រា២.a)
- លុបចោលច្បាប់ បទបញ្ជាទំនៀមទំលាប់ និងការប្រតិបត្តិមានស្រាប់ណា ដែលរើសអើងលើស្ត្រីភេទ ( មាត្រា២.f)
- ចាប់ប្រើប្រាស់វិធានការផ្លូវច្បាប់ ដើម្បីទប់ស្កាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ និងធានាថាស្ត្រីមានសិទ្ធិទទួលបាននូវការការពារពី ការរើសអើងតាមរយៈសាលាក្តីជាតិ និងស្ថាប័នសាធារណៈដទៃទៀត ( មាត្រា២. b និង c)
- បង្កើត និង/ឬពង្រឹងក្បាលម៉ាស៊ីនដឹកនាំជាតិ អោយមានប្រសិទ្ធភាព ដែលគាំទ្រដោយឥទ្ធិពលយេនឌ័រអោយ បានទូលំទូលាយទូទាំងក្រសួងមន្ទីររបស់រដ្ឋាភិបាល ដើម្បីផ្តល់ដំបូន្មានស្តីពីឥទ្ធិពលលើស្ត្រីនៃគ្រប់គោលនយោបាយរដ្ឋាភិបាលទាំងអស់ ត្រួតពិនិត្យស្ថានភាពស្ត្រីអោយបានហ្មត់ចត់ជួយបង្កើតគោលនយោបាយថ្មី អនុវត្តយុទ្ធសាស្ត្រនិងធានាវិធានការអោយមានប្រសិទ្ធភាព ដើម្បីលុបបំបាត់ចោលនូវការរើសអើង ។ (អនុសាសន៍ទូទៅលេខ៦)

## គំនិតការងារសំរាប់អនុវត្ត

- ធានាអោយមានសមភាព និងការមិនរើសអើងចំពោះច្បាប់ និងក្នុងការអនុវត្តន៍ផ្ទាល់ (ទិសដៅយុទ្ធសាស្ត្រ.L.2)
- បញ្ចូលទស្សនៈយេនឌ័រទៅក្នុងច្បាប់ គោលនយោបាយសាធារណៈ កម្មវិធីនិងគំរោង (ទិសដៅយុទ្ធសាស្ត្រ.H.2)
- បង្កើត និងផ្សព្វផ្សាយទិន្នន័យ និងព័ត៌មានទាក់ទងនឹងយេនឌ័រដែលបានបែកខ្ញែកពីគ្នាសំរាប់ការរៀបចំផែនការ និងការវាយតម្លៃ (ទិសដៅយុទ្ធសាស្ត្រ.H.3)
- បង្កើត ឬពង្រឹងក្បាលម៉ាស៊ីនដឹកនាំថ្នាក់ជាតិនិងស្ថាប័នរដ្ឋាភិបាលផ្សេងៗទៀត (ទិសដៅយុទ្ធសាស្ត្រ.H.1)



# គោលដៅ ទី ៣

# និងផ្តល់អំណាចដល់ស្ត្រី



រូបភាពដោយ : អង្គការសិលាការ



# កាត់បន្ថយអត្រាស្លាប់របស់កុមារ កែលំអសុខភាពមាតា

*សន្ធិសញ្ញា CEDAW និងកិច្ចប្រជុំបេក្កាំងបានចាត់ទុកថា ការលើកកម្ពស់និងលើកស្ទួយសិទ្ធិ ជាការចាំបាច់ដើម្បីលើក សុខភាព ក្នុងពេលជាមួយគ្នានៃស្ត្រី និងកុមាររបស់គេ ហើយជាការរួមចំណែកដល់គោលដៅទី៤ និងទី៥ ក៏ត្រូវ ត្រូវបានបកស្រាយច្បាស់ ។*

ដូចដែលក្រុមដោះស្រាយការងារសហសវត្សរ៍ ស្តីពីសុខភាពកុមារ និងសុខភាពមាតាបានកត់សំគាល់ថា ឧបសគ្គក្នុងការសំរេចគោលដៅទាំងនេះពុំមែនជាបច្ចេកទេស ប៉ុន្តែជាបញ្ហានៃការប្តេជ្ញាចិត្ត ។ របស់ សម្ភារៈបរិក្ខារ ដែលគេត្រូវការ ដើម្បីផ្តល់សេវាសុខភាពអោយបានសមរម្យ មិនចាំបាច់មានតំលៃថ្លៃទេ នាពេលបច្ចុប្បន្ននេះ ហើយសំរាប់ហេតុផលជាច្រើនដែលត្រូវតែធ្វើ ជាមួយនិងការពិចារណា ផ្នែកនយោបាយនៃការមិនទទួលបាននូវមូលនិធិគ្រប់គ្រាន់ ហើយនិងការធ្លាក់ចុះប្រព័ន្ធសុខភាពសាធារណៈដែលបណ្តាលមកពីការកែទំរង់សេដ្ឋកិច្ច ។

ចំពោះស្ត្រី និងកុមារ ចំហាំងនៃវិសមភាពយេនឌ័រដែលត្រូវបានបញ្ជ្រាប ក៏ដូចនៅក្នុងសង្គមសេដ្ឋកិច្ច វប្បធម៌ និងរចនាសម្ព័ន្ធនយោបាយបាន ប្រែក្លាយស្ថានភាពនេះកាន់តែធ្ងន់ធ្ងរឡើង ។ ការងារកម្មករកសិកម្មរបស់ និងរក្សាកម្ម ពីស្ត្រីធ្វើអោយពួកគេធ្វើការយ៉ាងខ្លាំង នូវសមត្ថភាពការពារសុខភាពផ្ទាល់ខ្លួន និងសុខភាពកូនរបស់គេ ដែលពួកគេត្រូវតែមាននូវម្ហូបអាហារបំប៉នគ្រប់គ្រាន់ ។ នៅក្នុងតំបន់ខ្លះកំរិតខ្ពស់នៃអត្រាមរណៈរបស់មាតា ដែលករណីនេះ ទាក់ទងជាមួយនិងវប្បធម៌ ដែលមិនអោយតំលៃដល់កុមារី ហើយផ្តល់អាទិភាពដល់កូនប្រុសល្អជាង ទាំងអាហារបំប៉ន និងការថែទាំសុខភាព ។ ចំណែកឯសូចនាករសុខភាពជាច្រើនផ្សេងៗ

ចំណុចដៅទី ៤ : កាត់បន្ថយអត្រាស្លាប់របស់កុមារអោយបាន២ភាគ៣ ក្នុងចំណោមកុមារដែលមានអាយុក្រោម ៥ឆ្នាំ ។

ចំណុចដៅទី ៥ : កាត់បន្ថយអត្រានៃការស្លាប់របស់មាតាអោយបាន ៣ភាគ៤ ។

# គោលដៅ ទី ៤ និង ៥



រូបភាពដោយ : អង្គការសិលការ




ទៀតបានប្រសើរឡើងជាងពីរ-បីទសវត្សរ៍កន្លងមកហើយ ដោយយើងឃើញអត្រាមរណៈរបស់មាតា បង្ហាញថា មានការផ្លាស់ប្តូរតិចតួច ។ បញ្ហានេះវាមិនបណ្តាលមកតែពីការខ្វះអ្នកមានវិជ្ជាជីវៈ សាស្ត្រដែលមានការបណ្តុះបណ្តាល និង មជ្ឈមណ្ឌល សុខភាពសំរាប់មាតុភាពប៉ុណ្ណោះទេ តែវាក៏បណ្តាល មកពីស្ត្រីមិនមានឱកាសគ្រប់គ្រងធនធាន ខ្វះអំណាចសម្រេចចិត្ត និងមានការដាក់កំរិតចំពោះសេរីភាព ដើរហើរក្រៅផ្ទះ នោះផងដែរ ។

ក្រុមដោះស្រាយការងារសហស្សវត្សរ៍ លើសមភាពយេនឌ័របានផ្តល់ដំបូន្មានថា នៅក្នុងផ្នែក សុខភាព "ប្រទេសទាំងអស់គួរតែដាក់អាទិភាពគោលនយោបាយ ដោយរួមទាំងការធ្វើគំរោងគ្រួសារ ការរំលូតកូនដោយសុវត្ថិភាព ការការពារ និងការព្យាបាលជំងឺឆ្លងផ្លូវភេទ និងការផ្តល់អាហារបំប៉ន ព្រមទាំងគោលនយោបាយ ដែលបង្កលក្ខណៈអោយស្ត្រីប្រសូតទារកដោយសុវត្ថិភាព ដោយធានាថារាល់ ការប្រសូតទាំងអស់ ត្រូវចូលរួម ដោយបុគ្គលិកពេទ្យ មានជំនាញសមស្រប ហើយធានាថាគ្រប់ស្ត្រីទាំងអស់ មានឱកាសទទួលបានសេវាសុខភាព ដោយផ្តល់ការការពារបន្ទាន់ដល់កំណើតកុមារ ក្នុងករណីការឆ្លងទន្លេ ដែលប៉ះពាល់ដល់អាយុជីវិត" ។

**ផ្នែកដែលសន្ធិសញ្ញា CEDAW និងកិច្ចប្រជុំប៉េកាំងគាំទ្រសិទ្ធិស្ត្រី**

រដ្ឋាភិបាលមានកាតព្វកិច្ចក្រោមកិច្ចព្រមព្រៀង CEDAW និងបានប្តេជ្ញាចិត្តក្រោមសេចក្តីប្រកាសនៃកិច្ចប្រជុំប៉េកាំង ដើម្បីចាត់តាំងនូវវិធានការទូលំទូលាយ ទាក់ទងនឹងការផ្តល់ការគាំពារសុខភាព ក្នុងគោលបំណងធានា ផលប្រយោជន៍ស្មើគ្នារវាងបុរស និងស្ត្រី ។ នៅពេលដែលការថែរក្សាសុខភាពត្រូវការមនុស្សទាំងពីរភេទចូលរួម ជាមួយគ្នានោះ សមភាពនៃឱកាសទទួលសេវាត្រូវតែមានការធានា ។ ប៉ុន្តែនៅពេលដែលស្ត្រីមានសេចក្តីត្រូវការ តួនាទី និងការទទួលខុសត្រូវ ខុសគ្នា ជាពិសេសទាក់ទងនឹងការមានផ្ទៃពោះ ការធ្វើគំរោងគ្រួសារ និងការផ្តល់អាហារបំប៉ន និងសុខមាលភាពរបស់គ្រួសាររបស់គេ រដ្ឋាភិបាលត្រូវតែមានវិធានការបន្ថែមជាចាំបាច់ ដើម្បីធានាថាសេចក្តីត្រូវការនោះក៏ត្រូវបានបំពេញផងដែរ ។ លើសពីនេះទៅទៀត នៅពេលដែលគោលដៅនៃ សុខភាពមាតា និងអត្រាមរណៈរបស់កុមារ មានជាប់ទាក់ទងយ៉ាងជិតស្និទ្ធជាមួយកាតព្វកិច្ចសន្ធិសញ្ញា CEDAW និងកិច្ចប្រជុំប៉េកាំងដែលទាក់ទងនឹងគំរោងផែនការអនាគតនៃការគាំពារសុខភាព ដែលសង្កត់ធ្ងន់លើការធានា សមភាពយេនឌ័រ នៅក្នុងវិស័យផ្សេងៗទៀត ហើយត្រូវធានាអោយស្ត្រីទទួលបាននូវអំណាចគ្រប់គ្រាន់ដើម្បី ស្រូបយកផល ប្រយោជន៍ពីសេវាដែលមាន ។



# កែលំអសុខភាពមាតា

គោលដៅ ទី ៤ និង ៥

## CEDAW

- លុបបំបាត់ ការរើសអើងនៅក្នុងវិស័យថែរក្សាសុខភាព ដើម្បីធានានូវសមភាពរវាងបុរស និងស្ត្រី ក្នុងឱកាសទទួលបានសេវាសុខភាពរួមទាំងអ្នកទាំងឡាយណាដែលទាក់ទងនឹងការធ្វើផែនការគ្រួសារ ។ (មាត្រា១២.១)

  ធានាសេវាសមស្របដល់ស្ត្រីទាក់ទងនឹងការមានផ្ទៃពោះ ពេលឆ្លងទន្លេ និងក្រោយពេលឆ្លងទន្លេ ដោយផ្តល់ការបំរើឥតគិតថ្លៃប្រសិនបើចាំបាច់ (មាត្រា ១២.២)
- ធានាផ្តល់អាហារបំប៉នដល់ស្ត្រីនៅពេលមានផ្ទៃពោះ និងពេលបំបៅដោះដល់កូន (មាត្រា១២.២)
- ធានាសិទ្ធិរបស់ស្ត្រីនៅជនបទទទួលបានសេវាសុខភាពគ្រប់គ្រាន់ រួមទាំងព័ត៌មាន ការប្រឹក្សានិងសេវាកម្ម ក្នុងការធ្វើផែនការគ្រួសារ (មាត្រា១៤.២.b)
- លុបបំបាត់ការរើសអើងនៅក្នុងការអប់រំក្នុងការ ធានាឱកាសរបស់ស្ត្រីទទួលបាននូវព័ត៌មានអប់រំដើម្បីធានា សុខភាព និងសុខមាលភាពគ្រួសារ រួមទាំងព័ត៌មាន និងដំបូន្មានអំពីការធ្វើផែនការគ្រួសារផងដែរ ។ (មាត្រា១០.h)

## វេទិកាប៉េកាំងសំរាប់ប្រតិបត្តិ

- បង្កើនឱកាសដល់ស្ត្រី ពេញមួយជីវិតដើម្បីទទួលបានការថែទាំសុខភាពឱ្យបានសមរម្យ គ្រប់គ្រាន់ និងប្រកបដោយគុណភាព ព្រមទាំងទទួលបានព័ត៌មាន និងសេវាកម្មផ្សេងៗ (ទិសដៅយុទ្ធសាស្ត្រ.C.1)
- ពង្រឹងកម្មវិធីទាក់ទងបង្ការទាំងឡាយ ដែលលើកស្ទួយដល់សុខភាពរបស់ស្ត្រី (ទិសដៅយុទ្ធសាស្ត្រ.C.2)
- អនុវត្តនូវគំនិតផ្តួចផ្តើមឆ្លើយតបនឹងយេនឌ័រ ដែលដោះស្រាយជំងឺឆ្លងតាមផ្លូវភេទ ជំងឺអេដស៍ និងបញ្ហាសុខភាពបន្តពូជ និងសុខភាពផ្លូវភេទ (ទិសដៅយុទ្ធសាស្ត្រ.C.3)
- លើកស្ទួយការស្រាវជ្រាវ និងផ្សព្វផ្សាយព័ត៌មានអំពីសុខភាពស្ត្រី (ទិសដៅយុទ្ធសាស្ត្រ.C.4)
- ពង្រីកធនធាន និងត្រួតពិនិត្យការតាមដានចំពោះសុខភាពស្ត្រី (ទិសដៅយុទ្ធសាស្ត្រ.C.5)
- លុបបំបាត់ការរើសអើងចំពោះនារីលើសុខភាព និងអាហារបំប៉ន (ទិសដៅយុទ្ធសាស្ត្រ.L.5)

# ប្រយុទ្ធប្រឆាំងនឹង ជំងឺអេដស៍/ហ៊ីវ ជំងឺគ្រុនចាញ់ និងជំងឺផ្សេងៗ



ចំណុចដៅ ទី ៧៖
បញ្ឈប់ និងបន្ថយការរីករាលដាលនៃជំងឺអេដស៍/ហ៊ីវ

ចំណុចដៅ ទី ៨៖
បញ្ឈប់ និងផ្តើមកាត់បន្ថយ គ្រោះថ្នាក់នៃជំងឺគ្រុនចាញ់ និងជំងឺផ្សេងៗ

យើងបាននឹងស្គាល់ ហើយថាវិសមភាពយេនឌ័រ គឺជាកត្តាមួយក្នុងចំណោមកត្តាសំខាន់ៗជាច្រើនដែល បញ្ហានេះកំពុងតែធ្វើអោយ ជំងឺអេដស៍/ហ៊ីវមានការរីករាលដាលយ៉ាងខ្លាំង។ ការបញ្ឈប់ និងការបន្ថយការរីករាលដាលនៃជំងឺអេដស៍/ហ៊ីវអាស្រ័យលើជោគជ័យនៃការខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងនឹងភាពបន្ទាបនៃវិសមភាពយេនឌ័រដែលមានឫសគល់ជ្រាលជ្រៅ និងមានទំនាក់ទំនងគ្នាទៅវិញទៅមក ដែលរួមផ្សំគ្នាធ្វើអោយស្ត្រីងាយរងគ្រោះទៅក្នុងជំងឺនោះ ។ បទដ្ឋានវប្បធម៌ដែលមិនយល់ដឹងអំពីផ្លូវភេទនិងភាពបរិសុទ្ធរបស់ស្ត្រីភាគឱកាស របស់គេក្នុងការទទួលបាននូវព័ត៌មានអំពីការការពារខ្លួន។ អតុល្យភាពអំណាចនៃយេនឌ័រ ធ្វើអោយស្ត្រីមានការលំបាកក្នុងការចរចាអំពីការប្រតិបត្តិរួមភេទប្រកបដោយសុវត្ថិភាពជាមួយដៃគូ ហើយការពឹងពាក់ផ្នែកសេដ្ឋកិច្ច និងការភ័យខ្លាចកើតមានអំពើហិង្សាជំរុញអោយពួកគេយល់ព្រម រួមភេទដោយមិនមានការការពារ។ ស្ត្រីកំពុងមិនបានទទួលការការពារ និងការព្យាបាលដោយគ្រប់គ្រាន់ពីព្រោះអ្វីដែលត្រូវទទួលនោះ ត្រូវបានគេដកហូតយកដោយផ្ទាល់ពីពួកគេ ហើយអ្វី ដែលកំពុងផ្តល់អោយមិនអាចទទួលយកបាន និងមិនសមស្រប តាមតំរូវការសុខភាពរបស់ពួកគេ ។ បន្ទុកនៃការថែទាំសមាជិកនៅក្នុង



រូបភាពដោយ : អង្គការ comfrel



គ្រួសាររបស់គេ និងសំរាប់ខ្លួនរបស់គេផ្ទាល់ បានសង្កត់យ៉ាងធ្ងន់ធ្ងរទៅលើគ្រួសារធ្វើអោយធ្លាក់ចូលទៅក្នុងភាពក្រីក្រ និងគ្មានចំណីអាហារ ខ្វះទីជំរកស់នៅ ពីព្រោះស្ត្រីខ្វះឱកាសទទួលនូវធនធានសេដ្ឋកិច្ច ព្រមទាំងទទួលផលប៉ះទង្គិចយ៉ាងធ្ងន់ធ្ងរ ដោយសារគ្មានការគាំទ្រ ពីសង្គមសំរាប់អ្នកដែលកំពុងត្រូវការ ។ យុទ្ធសាស្ត្រ ឆ្លើយតបទៅនឹងវិបត្តិជំងឺអេដស៍បានខកខានមិនបានដាក់ បញ្ចូលទស្សនៈយេនឌ័រនៅក្នុងការវាស់វែងទ្រង់ទ្រាយធំ ពីព្រោះស្ត្រីមិនមានឱកាសចូលរួមសកម្មនិងពេញលេញ ក្នុងការបង្កើតគោលនយោបាយជំងឺអេដស៍ទេ ។

**អ្វីដែលសន្ធិសញ្ញា** CEDAW **និងកិច្ចប្រជុំប៉េកាំងដែលតំរូវឱ្យធ្វើ**

ទំហំដ៏ធំទូលាយនៃគំរោងផែនការអនាគតរបស់សន្ធិសញ្ញា CEDAW និងកិច្ចប្រជុំប៉េកាំង អាចអនុវត្តបានក្នុងកិច្ចខិតខំប្រឹងប្រែង ដើម្បីឆ្លើយតបទៅនឹងជំងឺហ៊ីវ/អេដស៍ បន្ថែមទៅនឹងគំរោងផែនការ អនាគតជាក់លាក់របស់គេ ទាក់ទងទៅនឹងការគាំពារសុខភាព ។ ដោយសារតែ វិសមភាពយេនឌ័រ និងជំងឺអេដស៍មានទំនាក់ទំនងគ្នាទៅវិញទៅមក តាមវិធីផ្សេងៗគ្នាជាច្រើន ការប្រឈមមុខចំពោះការកាត់បន្ថយការរីករាលដាលនៃជំងឺអេដស៍ ត្រូវការការអនុវត្តន៍ នៃគំរោងផែនការទាំងនោះនៅពេលជំណាលគ្នា ។ វិធានការ ត្រូវតែធ្វើឡើងលើវិស័យសមភាពសេដ្ឋកិច្ចរបស់ស្ត្រី និងការផ្តល់អំណាចសមភាពក្នុងអាពាហ៍ពិពាហ៍ និងទំនាក់ទំនងគ្រួសារ សេវាកម្មគាំពារសុខភាព ការលុបបំបាត់ចោលនូវអំពើហិង្សាដោយសារយេនឌ័រ ការកែប្រែផ្នត់គំនិតសង្គមវប្បធម៌ដែលផ្អែកលើយេនឌ័រ និង ការជំរុញការចូលរួមក្នុងឆាកនយោបាយរបស់ស្ត្រី ។

# ជំងឺគ្រុនចាញ់និងជំងឺផ្សេងៗ



## CEDAW

- លុបបំបាត់ចោលនូវផ្នត់គំនិតសង្គម និងវប្បធម៌និងការប្រតិបត្តិផ្អែកលើវិសមភាពយេនឌ័រ (មាត្រា ៥.a)
- លុបបំបាត់ចោលនូវរាល់ទម្រង់នៃអំពើហិង្សាផ្អែកលើយេនឌ័រមកលើស្ត្រី (អនុសាសន៍ទូទៅលេខ១៩)
- លុបបំបាត់ចោលនូវការរើសអើងចំពោះស្ត្រីដើម្បីធានាសិទ្ធិស្មើគ្នារវាងបុរស និងស្ត្រីក្នុងការងារ (មាត្រា ១១)
- ធានាសិទ្ធិស្របច្បាប់ស្មើគ្នារវាងបុរស និងស្ត្រីទាក់ទងនឹងកិច្ចសន្យា និងទ្រព្យសម្បត្តិ (មាត្រា១៥)
- ធានានូវសិទ្ធិស្មើគ្នារវាងបុរស និងស្ត្រីក្នុងអាពាហ៍ពិពាហ៍ និងជីវិតគ្រួសារ (មាត្រា១៦)
- ធានានូវឱកាសស្មើគ្នារបស់ស្ត្រីក្នុងការទទួលនូវសេវាថែទាំសុខភាព (មាត្រា១២.១)
- ចៀសវាងការរើសអើងចំពោះស្ត្រីនៅក្នុងយុទ្ធសាស្ត្រថ្នាក់ជាតិសំរាប់ការការពារ និងការគ្រប់គ្រងជំងឺអេដស៍ (អនុសាសន៍ទូទៅលេខ ១៥)
- ធានាចំពោះស្ត្រីនូវសិទ្ធិចូលរួមក្នុងការបង្កើត និងការអនុវត្តន៍គោលនយោបាយរបស់រដ្ឋាភិបាល និងមានមុខតំណែងសាធារណៈ និងអនុវត្តមុខងារសាធារណៈនៅគ្រប់លំដាប់ថ្នាក់ក្នុងរដ្ឋាភិបាល (មាត្រា៧.b)*

## វេទិកាប៉េកាំងសំរាប់ប្រតិបត្តិ

- លុបបំបាត់ចោលនូវឥរិយាបថ និងការប្រតិបត្តិវប្បធម៌អវិជ្ជមានចំពោះនារី (ទិសដៅយុទ្ធសាស្ត្រ L.2)
- ចាត់វិធានការដាក់បញ្ចូលគ្នាដើម្បីទប់ស្កាត់ និងលុបបំបាត់អំពើហិង្សាលើស្ត្រី (ទិសដៅយុទ្ធសាស្ត្រ.D.1)
- លើកស្ទួយសិទ្ធិសេដ្ឋកិច្ចរបស់ស្ត្រី និងភាពម្ចាស់ការរួមទាំងឱកាសទទួលបានការងារ លក្ខខណ្ឌការងារសមរម្យ និងការគ្រប់គ្រងលើធនធានសេដ្ឋកិច្ច (ទិសដៅយុទ្ធសាស្ត្រ.F.1)
- បង្កើនឱកាសក្នុងជីវិតរបស់ស្ត្រីឱ្យទទួលបានការថែទាំសុខភាពសមរម្យ ដែលមានលទ្ធភាពគ្រប់គ្រាន់ និងប្រកបដោយគុណភាព ព្រមទាំងទទួលបានព័ត៌មាននិងសេវាដែលពាក់ព័ន្ធផ្សេងៗ (ទិសដៅយុទ្ធសាស្ត្រ .C.1)
- អនុវត្តនូវគំនិតផ្តួចផ្តើមឆ្លើយតបយេនឌ័រ ដើម្បីដោះស្រាយជំងឺឆ្លងតាមផ្លូវភេទ ជំងឺអេដស៍ និងបញ្ហាសុខភាពបន្តពូជ និងសុខភាពផ្លូវភេទ (ទិសដៅយុទ្ធសាស្ត្រ.C.3)
- ចាត់វិធានការដើម្បីធានាឱកាសស្មើគ្នារបស់ស្ត្រី និងការចូលរួមពេញលេញក្នុងរចនាសម្ព័ន្ធអំណាច និងការធ្វើសេចក្តីសំរេចចិត្ត (ទិសដៅយុទ្ធសាស្ត្រ G.4)



# ធានានិរន្តរភាពបរិស្ថាន

ដោយសារតែមានការបែងចែកតួនាទីតាមយេនឌ័រ ស្ត្រីក្នុងតំបន់ជាច្រើនតែពឹងលើការទាញយកការទទួលខុសត្រូវផ្សេងៗ ចំពោះការងារកសិកម្ម ការដងទឹក រកអុស និងការផ្គត់ផ្គង់ចំណីអាហារ ដល់ក្រុមគ្រួសាររបស់ពួកគេ ។ ការខូចខាតបរិស្ថាន ការខ្វះឱកាសកាន់កាប់ និងគ្រប់គ្រងធនធានធម្មជាតិបណ្តាលឱ្យមាន ផលប៉ះពាល់ធ្ងន់ធ្ងរទៅលើស្ត្រី ។ ឧទាហរណ៍ ដោយសារធនធានដែលកំពុងតែធ្វើឱ្យឱកាសទទួលបានការផ្គត់ផ្គង់ទឹកស្អាតកាន់តែថយចុះតិចទៅៗ ដូចជា ការបំពុលបរិស្ថាន ការធ្វើឯកជនភាវូបនីយកម្មលើសេវាកម្មទឹក ការផ្តល់សេវាកម្មអន់ថយនិងសម្ពាធពីកំណើនប្រជាពលរដ្ឋនេះតែកើនច្រើនឡើង នោះ បន្ទុកការងារដែលធ្លាក់ទៅលើស្ត្រីកាន់តែធ្ងន់ធ្ងរឡើងៗ ។ ស្ត្រីក្រីក្រ និង កុមារ (ជាពិសេសក្មេងស្រី) កំពុងតែធ្វើដំណើរ យ៉ាងឆ្ងាយចេញពីផ្ទះ ស្វែងរកប្រភពទឹក ដែលនាំឱ្យពួកគេធ្លាក់ខ្លួនទៅក្នុងអំពើហិង្សា (ការបៀតបៀន) បង្កើននូវថ្ងៃធ្វើការដែលមានរួចហើយកាន់តែវែងឡើង និង កាត់បន្ថយពេលវេលា ដែលពួកនាងត្រូវចំអិនអាហារ និងរកប្រាក់ចំណូល កាន់តែតិច ។ ក្មេងស្រី ទាំងឡាយត្រូវបង្ខំចិត្តបោះបង់ចោលសាលារៀនដើម្បី ជួយដងទឹក ។ ជាជំរើសចុងក្រោយ ស្ត្រីទាំងនោះបង្ខំចិត្ត ប្រើប្រាស់ទឹកកខ្វក់ គុណភាពមិនល្អប្រើប្រាស់ ហើយគ្រោះថ្នាក់នេះប៉ះពាល់ដល់អាយុជីវិតនិង សុខភាពគ្រួសារ ។ លើសពីនេះទៅទៀត មេរោគអេដស៍/ជំងឺអេដស៍ បាន រាលដាលទៅក្នុងសមាជិកគ្រួសារ ដោយមិនមានឱកាស សមស្របទទួលបាន ទឹកប្រើប្រាស់តាមតម្រូវការ ដើម្បីថែរក្សាសមាជិកនៅក្នុងគ្រួសារអាច ធ្វើអោយសមត្ថភាពរបស់ស្ត្រី ដែលជាអ្នកមើលថែទាំគាំពារកាន់តែចុះថយ

ចំណុចដៅទី ៩: ដាក់បញ្ចូលគោលការណ៍នៃការអភិវឌ្ឍប្រកបដោយនិរន្តរភាពទៅក្នុងគោលនយោបាយ និងកម្មវិធីប្រចាំប្រទេស និងកាត់បន្ថយនូវការបាត់បង់ធនធានបរិស្ថាន ។

ចំណុចដៅទី ១០: កាត់បន្ថយពាក់កណ្តាលនៃសមាមាត្រប្រជាពលរដ្ឋ ដែលមិនមានទឹកស្អាតប្រើប្រាស់ប្រកបដោយនិរន្តរភាព ។

ចំណុចដៅទី ១១: សំរេចឱ្យបាននូវការលូតលាស់សំខាន់ៗ នៅក្នុងជីវិតរបស់អ្នករស់នៅតាមតំបន់អនាធិបតេយ្យយ៉ាងហោចណាស់ ១០០លាននាក់ត្រឹមឆ្នាំ២០២០ ។



គោលដៅទី ៧
រូបភាពដោយ : អង្គការសិលាការ




ឬបាត់បង់ទាំងស្រុង ហើយ បង្កើនអត្រាស្លាប់ដោយសារ ជំងឺរាគ ។

តាមរយៈការទទួលខុសត្រូវរបស់ពួកគេទាក់ទិននឹងធនធានបរិស្ថានសំខាន់ៗ ស្ត្រីបានអភិវឌ្ឍ បង្កើតចំណេះដឹងដ៏មានតម្លៃអំពីនិរន្តរភាពបរិស្ថាន និងដើរតួជាស្នូលសំខាន់ដល់អាយុជីវិតនៃបរិស្ថានរបស់ពួកគេ ។ ទោះបីជា យ៉ាងណាក៏ដោយ វិសមភាពយេនឌ័រនិងការរើសអើងបានដកហូតអំណាចនៃការសម្រេចចិត្តដ៏ចាំបាច់ពីស្ត្រី មិនឱ្យឈានទៅជួយសម្រេចគោលដៅទាំងនេះបាន ។ ស្ត្រីត្រូវបានគេបដិសេធឱកាសទទួលបានព័ត៌មាន បច្ចេកវិទ្យា និងធនធានទាំងឡាយ ដែលធ្វើអោយពួកគេអាចចូលរួមនៅក្នុងការប្រតិបត្តិប្រកបដោយនិរន្តរភាពខាងបរិស្ថាន ឱ្យបានកាន់តែច្រើនថែមទៀត ឧទាហរណ៍ ដូចជានៅក្នុងប្រទេសទាំងឡាយដែលគេមិនបានធានាការការពារសិទ្ធិ របស់ស្ត្រីចំពោះ ភាពជាម្ចាស់ កាន់កាប់ដីធ្លី ជាដើម ។ ដូចដែលក្រុមដោះស្រាយការងារសហស្សវត្សរ៍ ស្តីអំពី បរិស្ថានបានបញ្ជាក់ស្រាប់ " នៅពេលដែលស្ត្រីខ្វះនូវ ចំណេះដឹង មធ្យោបាយ ឬសិទ្ធិអំណាច ដើម្បីគ្រប់គ្រង ធនធានធម្មជាតិ ដែលពួកគេពឹងផ្អែកដោយផ្ទាល់ ការខូចខាតធនធានទាំងឡាយនេះកើតឡើងមានកាន់តែច្រើន "។ ការខ្វះការគ្រប់គ្រងដោយផ្ទាល់ទៅលើធនធានទាំងនេះ ឆ្លុះបញ្ចាំងអោយឃើញ ថាស្ត្រី និងទស្សនៈរបស់ពួកគេ នៅតែមានការខ្វះចន្លោះ នៅគ្រប់ផ្នែកនៃការបង្កើតគោលនយោបាយ និងការសំរេចចិត្ត នៅលើជាប់ថ្នាក់ ទទួលខុសត្រូវលើការគ្រប់គ្រង ការអភិរក្ស និងការត្រួតពិនិត្យ បរិស្ថាននិងធនធានធម្មជាតិ ។

## អ្វីដែលសន្ធិសញ្ញា CEDAW និងកិច្ចប្រជុំប៉េកាំងតម្រូវឱ្យធ្វើ

ក្រោមសម័យប្រជុំ CEDAW និងកិច្ចប្រជុំប៉េកាំង រដ្ឋាភិបាលត្រូវតែធានាថា ស្ត្រីជាពិសេសស្ត្រីជនបទ ចូលរួមនៅក្នុងការសំរេចចិត្តនៅគ្រប់កំរិតដែលទាក់ទងទៅនឹងនិរន្តរភាពនៃបរិស្ថាន និងធានាថា ការព្រួយបារម្ភ និងទស្សនៈរបស់ស្ត្រី ត្រូវឆ្លុះបញ្ចាំងឱ្យបានសមស្របនៅក្នុងគោលនយោបាយ និងវិធីសាស្ត្រទាំងអស់ ដែលបានអនុម័ត ។ លើសពីនេះទៀត រដ្ឋាភិបាលត្រូវធានាថាស្ត្រីមានឱកាស និងការគ្រប់គ្រងលើធនធានបរិស្ថាន សំខាន់ៗមួយចំនួនដូចជាទឹក និងដីធ្លី ដែលត្រូវការជាចាំបាច់ ទាំងកិច្ចការពារស្ត្រីពីផលប៉ះពាល់ នៃការបាត់បង់បរិស្ថានទាំងការបង្កលក្ខណៈអោយពួកគេទាមទារវិធានការចាំបាច់ កែលំអបរិស្ថានរបស់គេ ។



# គោលដៅទី ៧

## CEDAW

- យកចិត្តទុកដាក់ទៅលើបញ្ហាសំខាន់ៗដែលស្ត្រីនៅតាមតំបន់ដាច់ស្រយាលជួបប្រទះនិងតួនាទីសំខាន់ៗដែល ស្ត្រីតាមទីជនបទអនុវត្តនៅក្នុងជីវភាពសេដ្ឋកិច្ចគ្រួសាររបស់ពួកគេ (មាត្រា១៤.1)
- ធានាសិទ្ធិរបស់ស្ត្រីក្នុងការចូលរួមលុបបំបាត់ អនុវត្ត នូវគម្រោងអភិវឌ្ឍន៍នៅគ្រប់កំរិត (មាត្រា១៤.២.a)
- ធានាថាស្ត្រីជនបទទទួលបាននូវឥណទានកសិកម្ម និងប្រាក់កម្ចី បរិក្ខារទីផ្សារ បច្ចេកវិទ្យាសមស្រប និង ការអនុវត្តន៍ប្រកបដោយសមធម៌ស្មើៗគ្នាក្នុងការចាត់ចែងដីធ្លី និងការកែទម្រង់ដីកសិកម្មព្រមទាំងគំរោងការតាំងទីលំនៅឡើងវិញ (មាត្រា១៤.២.g)
- ធានាឱ្យបានថា ស្ត្រីតាមជនបទដាច់ស្រយាលបានទទួលផលប្រយោជន៍ពីស្ថានភាពរស់នៅពេញលេញ ជាពិសេសទាក់ទងនឹងផ្ទះសំបែង អនាម័យ អគ្គិសនី និងការផ្គត់ផ្គង់ទឹក ព្រមទាំងការដឹកជញ្ជូន និងគមនាគមន៍ (មាត្រា១៤.២.h)

## វេទិកាបេកាំងសំរាប់ប្រតិបត្តិ

- អោយស្ត្រីបានចូលរួមយ៉ាងសកម្មនៅក្នុងការសំរេចចិត្តទាក់ទងនឹងបរិស្ថាននៅគ្រប់កំរិត (ទិសដៅយុទ្ធសាស្ត្រ K.1)
- ដាក់បញ្ចូលការងារ និងទស្សនៈយេនឌ័រទៅក្នុងគោលនយោបាយនិងកម្មវិធីសំរាប់ការអភិវឌ្ឍន៍យូរអង្វែង (ទិសដៅយុទ្ធសាស្ត្រ.K.2)
- ពង្រឹង ឬបង្កើតយន្តការនៅតាមកំរិតជាតិ តំបន់ និងអន្តរជាតិដើម្បីវាស់ប្រមាណមើលនូវផលប៉ះពាល់ពីការអភិវឌ្ឍន៍និងគោលនយោបាយបរិស្ថានទៅលើស្ត្រី (ទិសដៅយុទ្ធសាស្ត្រ.K.3)



# ពង្រីកភាពជាដៃគូ ពិភពលោកដើម្បី ការអភិវឌ្ឍន៍

ចំណុចដៅទី ១២ :
រៀបចំបន្ថែមទៀតនូវប្រព័ន្ធ ហិរញ្ញវត្ថុ និងពាណិជ្ជកម្មដែល មិនរើសអើងអាចប៉ាន់ ប្រមាណបានដោយពឹងផ្អែក លើច្បាប់ និងការបើកចំហ ។

ចំណុចដៅទី ១៧ :
សហការជាមួយក្រុមហ៊ុន ឱសថដែលអាចផ្តល់ថ្នាំសំខាន់ ចាំបាច់ និងតំលៃថោកល្មម ដល់ប្រជាជននៅក្នុងប្រទេស កំពុងអភិវឌ្ឍ ។

ចំណុចដៅទី ១៨ :
សហការជាមួយផ្នែកឯកជន ដើម្បីទាញផលប្រយោជន៍ពី បច្ចេកវិទ្យាថ្មីៗ ជាពិសេស បច្ចេកវិទ្យាទំនាក់ទំនង និងព័ត៌មាន ។

ការដាក់បញ្ចូលគោលដៅសំរាប់ការអភិវឌ្ឍន៍ ភាពជាដៃគូសាកល ត្រូវតែទាញការយល់ដៃគូ អភិវឌ្ឍន៍ទាំងអស់ ទៅលើបរិយាកាសសេដ្ឋកិច្ចនិង នយោបាយដែលប្រទេសនីមួយៗមិនគង់ ដើម្បីសំរេច អោយបាននូវគោលដៅ អភិវឌ្ឍន៍សហស្សវត្សរ៍ ។ ដូច្នេះត្រូវតែដៃគូអភិវឌ្ឍន៍ទាំងអស់ដែលមានឥទ្ធិពលលើសកលលោកគាប់ ទាំងស្ថាប័ន ពាណិជ្ជកម្ម និងហិរញ្ញវត្ថុអន្តរជាតិនៃរដ្ឋាភិបាល ម្ចាស់ជំនួយ និងប្រព័ន្ធអង្គការសហប្រជាជាតិ ព្រមទាំងវិស័យឯកជនត្រូវរួមយ៉ាង សកម្មក្នុងការថែរក្សាបរិយាកាសល្អប្រសើរ សំរាប់ការអភិវឌ្ឍន៍សហស្សវត្សរ៍ នោះទើបដំណើរការសហប្រតិបត្តិការទាំងមូលមិនមានការគំរាមកំហែង ។ វាមិនអាចជៀសផុតបានទេរាល់ការប្តេជ្ញាចិត្តដែលរដ្ឋាភិបាលនៃប្រទេស នីមួយៗធ្វើឡើង ដើម្បីអនុវត្តនូវការផ្លាស់ប្តូរដែលកំណត់ដោយគោលដៅ អភិវឌ្ឍន៍សហស្សវត្សរ៍ ហើយកិច្ចការទាំងអស់នោះនៅតែមិនអាចបំពេញ បានទេប្រសិនបើធនធានត្រូវការ និងភាពបត់បែននៃការបង្កើតគោល នយោបាយនៅតែខ្វះខាត ។

ការព្រួយបារម្ភតែងតែមានទំនាក់ទំនងចំពោះជាសក្តានុពលរវាង យុទ្ធសាស្ត្រដែលទាមទារដើម្បីសំរេច អោយបាននូវគោលដៅអភិវឌ្ឍន៍ សហស្សវត្សរ៍ ហើយនិងក្របខណ្ឌនៃការបង្កើតគោលនយោបាយសេដ្ឋ កិច្ចនិងពាណិជ្ជកម្ម នៅកំរិតជាតិ និងពិភពលោក រួមទាំងយុទ្ធសាស្ត្រនៃការ កាត់បន្ថយភាពក្រីក្រ ។ ឧទាហរណ៍ បើសិនជា ការសំរេចចិត្ត ត្រូវធ្វើឡើង ក្នុងកំរិតជាតិ និងកំរិតពិភពលោក ទាក់ទងនិងការទទួលជំនួយឧបត្ថម្ភជា

គោលដៅ ទី ៥



រូបភាពដោយ : អង្គការលីកាដូ

ប្រាក់ដែលមិនបានផ្តល់ផលចំណេញដល់ផលិតផលកសិកម្មរបស់ស្ត្រីក្រីក្រនោះទេ ហើយគ្រាន់តែជំរុញគំរោងឯកជនភាវូបនីយកម្ម ឧទាហរណ៍ជាក់ស្តែង បើតំលៃទឹកនៅតែមានកំរិតខ្ពស់លក់ជូនស្ត្រីក្រីក្រនោះមានន័យថា ស្ត្រីមិនបានទទួលជំនួយអភិវឌ្ឍន៍ក្រៅប្រទេស សំរាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍នោះទេ ទោះបីមានការខិតខំប្រឹងប្រែងអស់ពីសមត្ថភាពនៅតាមថ្នាក់ជាតិ ក៏មិនអាចសំរេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍បានដែរ ។ គេគួរតែសង្កត់ធ្ងន់ផងដែរ ពីការទទួលខុសត្រូវរបស់រដ្ឋាភិបាលក្រោមគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ដែលត្រូវមានកាតព្វកិច្ចលើកស្ទួយសិទ្ធិមនុស្សរបស់ស្ត្រី និងលុបបំបាត់នូវទម្រង់នៃវិសមភាពយេនឌ័រដែលបានគូសបញ្ជាក់ ក្នុងឯកសារនេះ ។ សំរាប់មូលហេតុនេះផងដែរ ស្ថានភាពសេដ្ឋកិច្ច និងនយោបាយដ៏ទូលំទូលាយ ដែលធ្វើអោយ រីកចំរើនទៅមុខនៅក្នុងឆាកអន្តរជាតិ គួរតែបង្កើនការយល់ដឹងលើសិទ្ធិមនុស្សរបស់ស្ត្រី ជាជាងគ្រាន់តែចាត់ទុកថា ជាឧបសគ្គនោះ ។ ភាពជាអ្នកដឹកនាំរបស់ស្ត្រី និងការដាក់បញ្ចូលទស្សនៈសិទ្ធិមនុស្សជាស្ត្រីនៅកំរិតអន្តរជាតិមានសារៈសំខាន់ខ្លាំងណាស់ ក្នុងការធានានូវការសំរេចចិត្តត្រឹមត្រូវ ដែលត្រូវធ្វើឡើង ។

**អ្វីដែលសន្ធិសញ្ញា** CEDAW **និងកិច្ចប្រជុំប៉េកាំងចែងទាក់ទង**

អ្នកជំនាញសិទ្ធិមនុស្សកំពុងបង្កើនការយកចិត្តដាក់ចំពោះការទទួលខុសត្រូវដែលស្ថាប័នពាណិជ្ជកម្ម និង ហិរញ្ញវត្ថុអន្តរជាតិ ស្ថិតក្រោមស្តង់ដារសិទ្ធិមនុស្សដូចជាសន្ធិសញ្ញា CEDAW ។ ក្រៅពីនេះពួកគេបានគូសបញ្ជាក់ថា រដ្ឋាភិបាលមិនគ្រាន់តែមានកាតព្វកិច្ចចំពោះប្រជាពលរដ្ឋរបស់គេក្រោមសន្ធិសញ្ញាសិទ្ធិមនុស្សប៉ុណ្ណោះទេ រដ្ឋាភិបាលដែលមានអំណាចបោះឆ្នោតផ្ទៃក្នុង និងផ្តល់មូលនិធិទៅដល់ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ត្រូវតែអោយគោរព ការតាំងចិត្តចំពោះសិទ្ធិមនុស្សនៅក្នុងបរិបទនេះផងដែរ ។ កិច្ចប្រជុំប៉េកាំងក៏បង្ហាញយ៉ាងច្បាស់ អោយរដ្ឋាភិបាល ធានាថាមានការសមស្របក្នុងការត្រួតពិនិត្យលើសមភាពយេនឌ័រក្នុងសកម្មភាពរបស់ពួកគេនៅកំរិតអន្តរជាតិ ។ លើសពីនេះទៅទៀតទាំងសន្ធិសញ្ញា CEDAW និងកិច្ចប្រជុំប៉េកាំង បញ្ចូលគំរោងផែនការវិធានការ ដែលទាមទារ កិច្ចប្រតិបត្តិការ ដើម្បីធានាថាស្ត្រីនិងទស្សនវិស័យរបស់ស្ត្រី លើកឡើងយ៉ាងសំខាន់ នៅក្នុងការសំរេចចិត្ត ផ្នែកនយោបាយគ្រប់កំរិតទាំងអស់ ។



# ដើម្បីការអភិវឌ្ឍន៍

គោលដៅ ទី ៨

## CEDAW

- ធានាដល់ស្ត្រីនូវឱកាស ដើម្បីធ្វើជាតំណាងរបស់រដ្ឋាភិបាលរបស់ពួកគេនៅកំរិតអន្តរជាតិនិងចូលរួមក្នុងកិច្ចការអង្គការអន្តរជាតិ (មាត្រា ៨)
- ធានាដល់ស្ត្រីនូវសិទ្ធិចូលរួមនៅ ក្នុងការបង្កើតនិងការអនុវត្តន៍គោលនយោបាយរដ្ឋាភិបាល និងកាន់កាប់ ការិយាល័យសាធារណៈ និងប្រកាន់យកនូវមុខនាទីសាធារណៈនៅគ្រប់កំរិតរបស់រដ្ឋាភិបាល (មាត្រា ៧.b)
- ធានាដល់ស្ត្រីនូវសិទ្ធិចូលរួមនៅក្នុងអង្គការ និងសមាគម មិនមែនរដ្ឋាភិបាលដែលទាក់ទងនឹងអាយុជីវិត នយោបាយរបស់ប្រទេសជាតិជាសាធារណៈ (មាត្រា ៧.c)
- ធានាដល់ស្ត្រីជនបទនូវសិទ្ធិចូលរួមក្នុងការពិភាក្សានិងការអនុវត្តន៍នៃគំរោងផែនការអភិវឌ្ឍន៍នៅគ្រប់កំរិត (មាត្រា១៤.២.a)

## វេទិកាប៉េកាំងសំរាប់សកម្មភាព

- ពិនិត្យមើលឡើងវិញ អនុម័ត និងថែរក្សាគោលនយោបាយសេដ្ឋកិច្ចម៉ាក្រូ និងយុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍ ដែលអាចដោះស្រាយនូវតំរូវការ និងការខិតខំប្រឹងប្រែងរបស់ស្ត្រីក្នុងភាពក្រីក្រ (ទិសដៅយុទ្ធសាស្ត្រ A.1)
- ចាត់វិធានការ ដើម្បីធានានូវឱកាសស្មើគ្នារបស់ស្ត្រី និងការចូលរួមពេញលេញនៅក្នុងរចនាសម្ព័ន្ធអំណាច និងការសំរេចចិត្ត (ទិសដៅយុទ្ធសាស្ត្រ.G.1)

# ធនធានព័ត៌មាននានាតាមប្រព័ន្ធអេឡិចត្រូនិច

CEDAW concluding comments and government reports for each country can be found at:
*http://www.un.org/womenwatch/daw/cedaw*

The CEDAW Committee's General Recommendations can be found at:
*http://www.un.org/womenwatch/daw/cedaw/recommendations.htm*

Summaries of the CEDAW sessions for each country can be found at:
*http://www.hri.ca/fortherecord2003/index.htm*

Country reports on follow-up measures taken to Beijing and Beijing +5 can be found at:
*http://www.un.org/womenwatch/daw/Review/responses.htm*

Documents relating to Beijing +5 can be found at:
*http://www.un.org/womenwatch/daw/folloeup/beijing+5.htm*

Documents relating to Beijing +10 can be found at:
*http://www.un.org/womenwatch/daw/csw/49sess.htm*

The reports of the Millennium Taskforces can be found at:
*http://www.unmillenniumproject.org/html/doc%20and%20reports.shtm*

National MDG reports can be found at:
*http://www.undp.org/mdg/country regionalreports.html*

A wide range of resources on gender equality and the MDGs can be found at:
*http://www.mdgender.net/*

# ឯកសារយោង


Millennium Project Task Force on Child Health and Maternal Health. 2004. Interim Report.
New York: Millennium Project.
*http://www.unmillenniumproject.org/html/tf4docs.shtm*

Millennium Project Task Force on Education and Gender Equality. 2004. Interim Report: From Promises to Action: Recommendations for Gender Equality and the Empowerment of Women.
New York: Millennium Project.
*http://www.unmillenniumproject.org/html/tf3docs.shtm*

Millennium Project Task Force on Environmental Sustainability. 2004. Interim Report.
New York: Millennium Project.
*http://www.unmillenniumproject.org/html/tf6docs.shtm*

Millennium Project Task Force on Poverty and Economic Development. 2004. Interim Report: An Enhanced Strategy for Reducing Poverty by the Year 2015.
New York: Millennium Project.
*http://www.unmillenniumproject.org/html/tf1docs.shtm*

United Nations Development Fund for Women. 2002. Progress of the World's Women 2002: Gender Equality and the Millennium Development Goals.
New York: UNIFEM.
*http://www.unifem.org/index.php?f page pid=10*

United Nations Development Fund for Women. 2001. Turning the Tide: CEDAW and the Gender Dimensions of the HIV/AIDS Pandemic.
New York: UNIFEM.
*http://www.unifem.org/index.php?f page pid=33*

# ឯកសារយោង


United Nations Development Programme. 2003. Human Development Report 2003. New York: Oxford University Press.

*http://hdr.undp.org/reports/global/2003/*

United Nations Development Programme. 2003. Millennium Development Goals: National Reports Through a Gender Lens. New York: UNDP.

*http://www.mdgender.net/resources/monograph detail.php?MonographID=8*

Women's Environment and Development Organization. 2004. Women's Empowerment, Gender Equality and the Millennium Development Goals: A WEDO Information and Action Guide. New York: WEDO.

*http://www.wedo.org/*

United Nations Development Fund for
Women (UNIFEM)
304 East 45th Street, 15th Floor
New York, NY 10017
USA
Tel:(212) 906-6400
Fax:(212) 906-6705
E-mail: unifem@undp.org
Website: www.unifem.org

Federal Ministry for Economic
Cooperation and Development (BMZ)
Friedrich-Ebert-Allee 40
D - 53113 Bonn
Germany
Website: www.bmz.de

Deutsche Gesellschaft für
Technische Zusammenarbeit (GTZ)
GmbH
Postfach 5180
D - 65726 Eschborn
Germany
Website: www.gtz.de/women_law